គណៈកម្មការទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ហ្លួងនិពទ្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនា: ព្រះគ្រូបញ្ញាលិក្ខិត កៅ-ស៊ុម អ្នកគ្រូតព្រាសិស្ស នៅសាលាបាលីជាន់ខ្ពស់

## បញ្ជីរឿង

*ផ្នែកអក្សរសាស្ត្រ* — ទំព័រ

ព្រះគ្រូសទ្ធវិទូ ពាង-សុខ . . . សុភាសិតប្រែជាពាក្យកាព្យ . . . . . . . . ៣៣៩
ព្រះគ្រូសិរីសោភ័ណ គីម-ឌូ . . រឿងកុមារពីរនាក់ជាមិត្រនឹងគ្នា . . . . . . . ៣៤៥
ហ្លួងនិពទ្ធមន្ត្រី ញ៉ុក-ថែម . . . ប្រវត្តិសាស្ត្រប្រទេសចិន (តមក) . . . . . ៣៥៣
ឃុនឧត្ដមប្រីជា ថាប-ពិន . . អធិប្បាយសុភាសិតខ្មែរ (តមក) . . . . . . ៣៦០
អ្នកឧកញ៉ាទេពពិទូរ ក្រសេម . . វណ្ណគតិ នារាយណទេសាវតារ (តមក) . . . . ៣៦៨

*ផ្នែកសាសនា*

ព្រះបាឡាត់គោធិកាម យូរ-ប៊ុណ្ណ សម្ពុលាជាតក . . . . . . . . . . . . ៣៧៤
លោកគ្រូព្រះអាចារ្យ ប៉ាង-ខាត់ អរិយសច្ចជាពុទ្ធភាសិត (តមក) . . . . . . . ៣៩៣

ឆ្នាំទី ១៧ - លេខ ៧ ខែស្ស៊ូយោគ ១៩៤៥ - ដំឡៃជាវ ១ ឆ្នាំ ១៥ រៀល ។

# សុភាសិតប្រែជាពាក្យកាព្យ

## ព្រះគ្រូសទ្ធម្មវិទូ ពាង - សុខ

ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

ឆ ឈាពុណោយ្យ ជន្តុ សេយ្យថាបិ កាកណ្ដកោ

ភជាតំ អតិមញ្ញេថ លទ្ធាន ឧឡ្ហមាសកំ ។

កុំធ្វើបុគ្គលយើង　កោងព្រហើនដូចបង្គួយ

ដែលស្ដេចប្រោសប្រាណជួយ　មិនឲ្យព្រួយព្រោះចំណី ។

បានមាសក(១) កន្ទុះ　ឡើងមានះ(២) ជាដែលខ្ពី

ពីងបុណ្យព្រះនរបតី(៣)　បលាស់(៤) គ្រោះភ្លូស(៥) ។

## កកណ្ដកប្បញ្ហា(៦)

កាលថ្ងៃ ១ ទៀត ព្រះរាជា(៧) បានយាងទៅឧទ្យានជាមួយនឹងបណ្ឌិត(៨) ។ កាលនោះ មានបង្គួយ ១ នៅលើចុងខ្លោងទ្វារ ។ វាឃើញព្រះរាជាកំពុងយាងមក ហើយចុះអំពីចុងខ្លោងទ្វារមកក្រាបលើ

---

១ ឈ្មោះមាត្រាប្រាក់ក្នុងបុរាណសម័យ ។ ២ សេចក្ដីក្រអឺតក្រទម ។ ៣ ម្ចាស់របស់មនុស្ស (ស្ដេច) ។ ៤ ដែលវង្វេងក្បួនទៀនឬកឲ្យស្មើ ។ ៥ សព្ទពិកាសា ប្រែថាក្ដៅទ្រទ្រង់ផែនដី (ស្ដេច) ។ ៦ ប្រស្នាដែលព្រះបាទវិទេហរាជទ្រង់សួរមហោសថបណ្ឌិត ព្រោះស្ដេចចង់ឲ្យប្រស្នានេះអាចក្នុងមហានិបាតវណ្ណនា តង់មហោសថជាតក ។ ៧ ស្ដេចក្នុងទីនេះសំដៅយក ព្រះបាទវិទេហរាជ ។ ៨ អ្នកប្រាជ្ញក្នុងទីនេះសំដៅយកមហោសថបណ្ឌិត ដែលប្រែថា អ្នកប្រាជ្ញមានថ្នាំកែរោគយ៉ាងសំខាន់ឬយ៉ាងពូកែ ។

ផែនដី ។ ព្រះរាជាទ្រង់ទតកិរិយារបស់វាហើយសួរថា នែបណ្ឌិត បក្សីនេះធ្វើអ្វី? បណ្ឌិតក្រាបទូលថា បពិត្រមហារាជ បក្សីនេះចង់ស្ទួនស្ពាលទឹកព្រះអង្គ ។ បើយ៉ាងនេះ ការស្ទួនស្ពាលទឹកយើង ចូរកុំឲ្យឥតផល អ្នកចូរប្រើបំរើឲ្យឲ្យភោគៈដល់វា ។ បពិត្រព្រះសម្មតិទេព(១) វាមិនមានកិច្ចដោយភោគៈទេ ត្រឹមតែចំណីប៉ុណ្ណោះបានហើយ ។ ចុះវាស៊ីអ្វី? បពិត្រព្រះសម្មតិទេព វាស៊ីសាច់ ។ បានសាច់ប៉ុន្មានគួរ? បពិត្រព្រះសម្មតិទេព បានសាច់មានតំលៃត្រឹមតែ ១ កាកណិក(២) គួរ ។ ព្រះរាជាបានបង្គាប់បុរសម្នាក់ថា ធម្មតាព្រះរាជអំណោយ(៣) ដែលត្រឹមតែ ១ កាកណិកមិនគួរទេ ឯងចូរយកសាច់ដែលមានតំលៃកន្លះមាសកមកឲ្យដល់បក្សីនេះកុំឲ្យដាច់ ។ បុរសនោះបានទទួលថា ព្រះករុណាថ្លៃវិសេស ហើយបានធ្វើដូច្នោះតាំងអំពីថ្ងៃនោះ ។ ក្នុងថ្ងៃ ១ បុរសនោះមិនបានសាច់ក្នុងថ្ងៃឧបោសថ ជាថ្ងៃដែលគេមិនត្រូវសំឡាប់សត្វ ហើយចោះមាសកពាក់កណ្ដាលនោះឯង រួចដោតដោយខ្សែតូចចងឲ្យជាគ្រឿងប្រដាប់ត្រង់កបក្សីនោះ ។ គ្រានោះ មានះក៏កើតដល់វាព្រោះអាស្រ័យគ្រឿងប្រដាប់នោះ ។ ក្នុងថ្ងៃនោះឯង ព្រះរាជាបានយាងទៅឧទ្យាន ។

---

១ ទេវតាដោយសន្មត (ស្ដេច) ។ ២ ទ្រព្យដែលមានតំលៃប៉ុនតំលៃនៃដុំសាច់ល្មមក្អែកចាំពាំទៅបាន: ជាឈ្មោះមាត្រាប្រាក់យ៉ាងតិចបំផុតក្នុងបុរាណសម័យ ។ ៣ អំណោយរបស់ស្ដេច, របស់ដែលស្ដេចប្រទាន ។

វាឃើញព្រះរាជាកំពុងយាងមក ធ្វើខ្លួនឲ្យស្រើទីងព្រះរាជា ដោយអំណាចមានៈដែលកើតព្រោះអាស្រ័យទ្រព្យ ថា បពិត្រព្រះបាទវិទេហៈ(១) ព្រះអង្គឬដែលមានទ្រព្យច្រើន? ឬក៏ខ្ញុំមានទ្រព្យច្រើន? ទើបមិនចុះ ឯកក្បាលក្រាបលើចុងខ្នងទ្វារតែម្តង ។ ព្រះរាជាបានទតកិរិយារបស់វាហើយ ទ្រង់ត្រាស់ សួរថា ហៃបណ្ឌិត បង្គួយនេះមិនចុះក្នុងថ្ងៃនេះដូចក្នុងថ្ងៃមុន តើហេតុដូចម្តេចហ្ន៎? ទើបទ្រង់ត្រាស់ព្រះគាថានេះ គឺ

នាយំ បុរេ ឧន្នមតិ តោរណគ្គេ កកណ្ដកោ
មហោសធ វិជានាហិ កេន ថទ្ធោ កកណ្ដកោ ៗ

ពីដើមបង្គួយ នេះ មិនគោង(២) ម្ល៉េះមហោសធ
ចាចូរចាប់ពិរុទ្ធ(៣) តើពុតត្បុតវាដូចម្តេច?

គ្រានោះបណ្ឌិតដឹងថា មានៈត្រូវកើតដល់បង្គួយនោះ ព្រោះអាស្រ័យមាសកពាក់កណ្ដាលដែលរាជបុរស ចងត្រង់ក ព្រោះមិនបានសាច់ក្នុងថ្ងៃឧបោសថ ជាថ្ងៃដែលគេមិនត្រូវសំឡាប់សត្វ ទើបបានពោលគាថានេះ គឺ

អលទ្ធបុព្វំ លទ្ធាន អឌ្ឍមាសកំ កកណ្ដកោ
អតិមញ្ញតិ រាជានំ វេទេហំ មិថិលគ្គហំ ៗ

---

១ ស្តេចដែលជាឥស្សរៈក្នុងវិទេហរដ្ឋ ស្តេចដែលសោយរាជ្យក្នុងដែនឈ្មោះវិទេហៈ ។
២ មិនក្រអឺតក្រអោង, មិនគឃ្លើន, មិនច្រឡើសបើស ។ ៣ ចាប់កំហុស ។

បន្ទយបានមាសក    ចិត្តអាក្រក់ក៏កើតឡើង

រាំត្រៀចូកបើងម៉ើង    មានះឡើងមើលងាយស្តេច ៗ

ព្រះកដាបានប្រើបំរើឲ្យហៅបុរសនោះមកហើយត្រាស់សួរ ៗ បុរសនោះក៏ក្រាបទូលតាមពិតតាមមែន ៗ ព្រះកដាទ្រង់ព្រះចិន្តាថា បណ្ឌិតបានដឹងអធ្យាស្រ័យរបស់បន្ទយ មិនបាច់សួរអ្នកណាមួយ ហាក់ដូចជាសព្វញ្ញូ ហើយជ្រះថ្លាណាស់ បានញុំាងបំរើឲ្យឲ្យគាស់កុន្ទ ទ្វារទាំង ៤ ដល់បណ្ឌិត ៗ ព្រះកដាក៏ខ្វាល់ទឹងបន្ទយ ប្រុងប្រៀបទឹងសំឡាប់បន្ទយនោះ ៗ ឯបណ្ឌិតបានឃាត់ព្រះកដាថា បពិត្រព្រះសម្មតិទេព ធម្មតាតិរច្ឆានមិនមានប្រាជ្ញាទេ បពិត្រព្រះសម្មតិទេព សូមព្រះអង្គទ្រង់ប្រទានអភ័យទោស ៗ

ចប់កកណ្ឌកបញ្ហា ៗ

## តំសាធកសុភាសិត[1]

ស្រូវទនតែងមានគ្រាប់    ស្រូវងើបជាប់គ្រាប់មិនមាន

ដូចជនដែលឈ្លានពាន    តែងតែមានព្យាបគ្រោះ ៗ

ឯជនដែលសុភាព    ឫកពាទាបពាក្យពីរោះ

តែងមានសោមគ្រោះ[2]    មានកេរ្តិ៍ឈ្មោះគ្រប់សាយ ៗ

---

១ សុភាសិតដែលញុំាងរឿងរ៉ាវចង្អុលនោះឲ្យសម្រេច ៗ ២ គ្រោះល្អ, គ្រោះជា ៗ

# ធម្មសង្វេគកាព្យ (១)

៙ បដិយត្ត មានះបង់ក ឲ្យស្មើបេស្ដា នៃព្រះនរបតី នាមល្បី សោះសា ព្រោះតែអាត្មា បានមាស់កពាក់ ៗ

មានះជាធម៌ ធ្វើឲ្យល្អក់ពណ៌ (២) ធ្វើឲ្យអាគល័ក្ខណ៍ ធ្វើសត្វឲ្យ សាប សូន្យលាភសូន្យភ័ក្ត្រ (៣) សូន្យពាក់ពំនាក់ សូន្យមគ្គសូន្យផល ៗ

# សារណាកថា (៤)

ព្រោះហេតុនោះ ពួកជនដែលបានវត្ថុជាទីស្រឡាញ់ - គាប់ចិត្ត - ពេញចិត្ត កុំជោរព្រោះតែវត្ថុនោះឡើយ បើមិនដូច្នោះទេ តែងតែជាអ្នកសាបសូន្យពាកវត្ថុនោះ ដូចជាបដិយដែលសាបសូន្យពាកចំណី ព្រោះតែមានះកើតអាស្រ័យមាសកពាក់កណ្ដាល ដែលកេជបុរសពោះ ដោតដោយខ្សែគួច ហើយចងឲ្យជាគ្រឿងប្រដាប់ក្រង់កនោះឯង ៗ

ចប់សុភាសិត ៗ

# សុប្ចកិរិយាគាថា

សច្ចំ វេ អមតា វាចា សច្ចំ ធារេន្តិ បណ្ឌិតា
ឯតេន សច្ចវជ្ជេន និប្បុតុ សត្ថុ សាសនន្តិ ៗ

---

១ កាព្យដែលប្រកាសនូវសេចក្ដីស្រងេះស្រងោច ឬលាន្លង់លន្លោចក្នុងធម៌ ៗ ២ គុណមានសីលជាដើម ៗ ៣ បំណី ៗ ៤ ពាក់ពោលរំឭក ឬ ដាស់តឿន ៗ

# គាថាសម្រាប់ផ្សងឬបួងសួង

ពាក្យពិតជាវាចា ប្រាជ្ញពោលថាពាក្យមិនស្លាប់

ពួកប្រាជ្ញតែងត្រងត្រាប់ ទ្រកាន់កាប់សព្វវាចា

ដោយពោលវាចាស័ត្យ(១) បណ្ឌិតចាត់ថាអមតា(២)

នេះសូមឲ្យសាសនា ព្រះសាស្ដាភ្លឺរុងរឿង ។

---

១ ពិត, មែន, ប្រាកដប្រជា ។ ២ ដែលមិនស្លាប់, ដែលមិនមានសេចក្ដីស្លាប់, ដែលដុយគ្មានឹងវិនាសស្លាប់ ។

# រឿងកុមារពីរនាក់ជាមិត្រនឹងគ្នា

ព្រះគ្រូសិរីសោភ័ណ កឹម-ធូ ក្រុមជំនុំព្រះត្រៃបិដក

រៀបរៀង

មានកុមារម្នាក់ឈ្មោះ ទុ ស្យហ៍ ជាកូនអ្នកនៅស្រុកក្រុង តាំងពីដើមក្តីឡើងកាលណា ជាក្មេងមានព្យាយាម មានគំនិតសណ្តាប់ធ្នាប់ល្អ ចេះគួរសមដល់ចាស់ព្រឹទ្ធាចារ្យ ធ្វើតាមដំបូន្មានរបស់ម្តាយឪពុក ។ ទាំងអ្នកឯទៀតក៏ស្រឡាញ់សរសើរស្ញើរតែគ្រប់គ្នា ។ កុមារ ទុ ស្យហ៍ នោះឯងលុះដល់អាយុ ១០ ឆ្នាំហើយ ក៏ចេះថែសំអាតខ្លួនប្រាណនិងស្លៀកសំលៀកបំពាក់យ៉ាងស្អាតបាត ចេះថែទាំបោសសំអាតផ្ទះ និងរៀបចំទុកដាក់សម្បត្តិដែលមាននៅក្នុងផ្ទះឲ្យគង់មានរបៀបរៀបរយល្អ កុមារ ទុ ស្យហ៍ នោះ កាលបើឃើញក្មេងឯទៀតកាន់សៀវភៅដើរទៅរៀនឯសាលារាល់ៗថ្ងៃ ក៏នឹកក្អកក្អួល ។ តែក្នុងចិត្តថា អញធ្វើម្តេចនឹងបានទៅរៀនដូចគេ ហើយក៏សួរម្តាយឪពុក ។ ដឹងថា កូនរបស់ខ្លួនចង់រៀនអក្សរ ក៏មានសេចក្តីត្រេកអរនាំកូនចូលសាលារៀន ។ កុមារ ទុ ស្យហ៍ តាំងពីថ្ងៃដែលបានចូលសាលារៀនមកមានព្យាយាមប្រឹងរៀន មិនចាំបាច់មានគេដាស់តឿនឡើយ វេលាចេញពីសាលាទៅដល់ផ្ទះ ក៏ដាក់សៀវភៅលើតុ ហើយផ្លាស់ខោអាវ ដងទឹកដាក់ពាងស្រោចដំណាំនៅជុំវិញផ្ទះរាល់ថ្ងៃ ពេលយប់ កុមារ ទុ ស្យហ៍ ខំរៀនទន្ទេញរហូតដល់ម៉ោង ១០ ឬ ១១

ទើបបានដេក ពេលព្រឹក ម៉ោង៥ កុមារទុស្សហ៍ក្រោកពីដេកឡើង ក៏ស្រូតរំពឹកមេរៀនដែលបានរៀនពីល្ងាច ចាំស្ទាត់គ្រប់ហើយក៏ច្បាស់ឡើង បោសសំអាតផ្ទះពីខាងលើខាងក្រោម ទីងរៀបទុកដាក់របស់ទ្រព្យស្រួលបួលហើយ ដល់ម៉ោងទៅសាលាក៏ចាប់សៀវភៅកាន់ដើរតម្រង់ទៅសាលារៀន កុមារទុស្សហ៍ប្រព្រឹត្តបែបនេះតែរាល់ថ្ងៃ ៗ

មានកុមារម្នាក់ទៀតឈ្មោះ កុស នៅស្រុកក្រៅជិតក្រុងដែរ តាំងពីដើមក្តីឡើង ជាកើតខ្ជិលច្រអូស ឥតគំនិត ឥតសណ្តាប់ធ្នាប់ មិនដឹងគួរសមដល់ចាស់ទុំ ម្ដាយឪពុកប្រៀនប្រដៅយ៉ាងណាក៏មិនរវល់ធ្វើតាម ម្ដាយឪពុកក៏ពាល់គំនិតមិនដឹងបើគិតធ្វើដូចម្ដេច សូម្បីអ្នកឯទៀតក៏ស្អប់ មិនចូលចិត្តដែរ កុមារកុសនោះ ដល់អាយុ ១១ ឆ្នាំហើយមិនចេះសំអាតខ្លួនទីនៅ គ្រឿងស្លៀកពាក់ ម្លោះហើយខ្លួនទីងសំពត់អាវប្រឡាក់ប្រឡូសដោយក្អែល បណ្ដាលកើតជាបូសមករមាស់ជាសពាសពេញទាំងខ្លួន វេលាដេកក៏ដេកទ្រមក់ វេលាស៊ីក៏ស៊ីច្រើន ម្ដាយឪពុកទំហាយល្បួងលោមឲ្យទៅនៅរៀនអក្សរឯវត្ត កុមារកុសប្រកែកថាខ្ញុំមិនចង់ទៅនៅទេ ៗ ម្ដាយឪពុក-ម៉េចក៏ឯងមិនព្រមទៅ ៗ កុមារកុស-ចាំបន្តិចទៀតទើបបានខ្ញុំទៅនៅ ៗ លេងឲ្យសប្បាយចិត្តសិន, ពោលជាខានក្រោយមកដោយខ្លាចពាក្យម្ដាយឪពុក ជាក់កំរិតបង្ខំយ៉ាងខ្លាំង កុមារកុសទ្រាំមិនបាន ក៏ព្រមស្មុខចិត្តថាទៅនៅវត្ត ម្ដាយឪពុកដឹងថា

កូនសុខចិត្តព្រមហើយ ក៏រកតែ១កញ្ចប់ ស្ករ១កញ្ចប់ ទឹងចំណីឯទៀត នាំចៅកុសកំដិលទៅប្រគេនលោកគ្រូឯវត្ត នៅមិនយូរប៉ុន្មានគ្រាន់តែបាន ៣-៤ថ្ងៃ ក៏គេចរត់ទៅនៅផ្ទះវិញ ម្ដាយឪពុកនាំយកទៅទុកវត្តម្ដងទៀត នៅមិនបានប៉ុន្មានថ្ងៃ ចៅកុសក៏ចេះតែគេចរត់ទៅផ្ទះដូចថ្ងៃមុនៗទៀត ដោយអាល័យនឹងការលេងពន់ពេក ម្ដាយឪពុកអស់គំនិតក៏គិតគ្នាថា កូនយើងបើវាខ្ជិលយ៉ាងហ្នឹងតើនឹងគិតដូចម្ដេចឲ្យវារៀនកើត ឪពុកក៏ភ្លក នឹកឃើញហើយក៏លាន់មាត់ប្រាប់ប្រពន្ធថា ឱ! ឯងអើយ អញមានសំ-ឡាញ់ម្នាក់នៅស្រុកក្រុងជាមនុស្សគួរសមនឹងគេដែរ បើដូច្នេះ កូនយើងឲ្យវានៅរៀនអក្សរវត្តជិតៗ នេះមិនបានទេ វាហៅរត់មកផ្ទះណាស់ យើងយកវាទៅឲ្យនៅឆ្ងាយពីផ្ទះ ប្រហែលគ្រាន់បើជាងនៅជិតនេះ ម្ដាយឪពុកគិតព្រមគ្នា ហើយក៏នាំចៅកុសជាកូនទៅទុកដាក់ឲ្យនៅនឹងផ្ទះសំ-ឡាញ់នៅស្រុកក្រុង ។ សំឡាញ់នោះក៏ទទួលរាក់ទាក់ដោយស្មោះសរ ហើយនិយាយថា អើសំឡាញ់ស្រួលហើយ អាឧស្សាហ៍កូនខ្ញុំបានចូលរៀនក្នុងសាលាតែសព្វថ្ងៃចំនួនជា ១ខែមកហើយ វេលាចេញពីសាលាមកផ្ទះនៅរៀនតែម្នាក់ឯង ត្រូវបានអាកុសកូនសំឡាញ់មកនៅជាមួយគ្រាន់នឹងបានជាគ្នារៀនតទៅ សំឡាញ់ទាំងពីរនាក់គិតគួរព្រមគ្នា ហើយនាំចៅកុសចូលសាលារៀនជាមួយនឹងចៅឧស្សាហ៍ដែរ ។ សំឡាញ់ស្រុកក្រៅទុកដាក់កូនរួចស្រេចហើយ ក៏លាសំឡាញ់ស្រុកក្រុងត្រឡប់ទៅ.

ផ្ទះវិញ ចៅស្រហ៍នឹងចៅកុសនៅរៀនជាមួយគ្នាតែរាល់ថ្ងៃ រាប់អាន ស្រឡាញ់គ្នាទៅវិញទៅមក ចំណែកចៅកុសតាំងពីចូលរៀនក្នុងសាលា បាន ៧-៨ ថ្ងៃកន្លងមក ក៏កើតសេចក្ដីខ្ជិលគ្រប់សង្កត់ រៀនមិនកើតចេះតែ គេចវេះខានរៀនក្នុង ១ អាទិត្យ ២ ថ្ងៃ ឬ ៣ ថ្ងៃ ថ្ងៃណាដែលបានទៅដល់ សាលាម្ដង ៗ មិនដែលទាន់ម៉ោងឡើយ រៀនក៏មិនសូវចាំភ្លេចមុខភ្លេច ក្រោយ វេលាចេញពីសាលារៀនមកផ្ទះ ក៏មិនយកចិត្តទុកដាក់ជួយធ្វើ កិច្ចការក្នុងផ្ទះ ទាំងមិនអើពើនឹងកិច្ចរៀនរបស់ខ្លួនសោះឡើយ លុះដល់ ឆ្នាំត្រូវប្រឡងក៏ប្រឡងមិនជាប់ មានឈ្មោះជាក្មេងខ្ជិលក្នុងសាលារៀន ចៅស្រហ៍ជាសំឡាញ់ឃើញចៅកុសខ្ជិលច្រអូសពេក ទំនិយាយដាស់ តឿនថាសំឡាញ់អើយ យើងត្រូវតែខំរៀនតម្រិះឲ្យចេះទាន់ខ្លួននៅក្មេង លុះដល់យើងចំរើនធំឡើង រវល់តែនឹងធ្វើការរកស៊ី នឹងមានពេល ឯណារៀនថ្នាបាន សមដូចពាក្យបុរាណលោកថា "ចេះមកពីរៀន មានមកពីរក" ចៅកុសកំជិល បើទុកជាចៅស្រហ៍ទំនិយាយដាស់តឿន យ៉ាងណា ៗ ក៏នៅតែព្រងើយ ៗ មិនអើពើធ្វើតាម ។ ចំណេរកាលជាទាន់ ក្រោយមក គ្រូបង្រៀនពិនិត្យទៅឃើញថាកែមិនឡើង ក៏បណ្ដេញ ចៅកុសកំជិលចេញពីសាលាបញ្ឈប់លែងឲ្យរៀន ។ ចៅកុសអស់សេចក្ដី សង្ឃឹមហើយ ត្រឡប់ទៅនៅផ្ទះម្ដាយឪពុករបស់ខ្លួនឯស្រុកវិញ ចៅ កុសដល់អាយុ ២០ ឆ្នាំហើយ ម្ដាយឪពុកគិតគ្នាថា អាកុសកូនយើង

កាន់តែពិណាស់ហើយទុកឲ្យវានៅលើវាលតយ៉ាងនេះ ទីងនាំតែតែខ្ជាប់
អសារផតការទៅទៀត ត្រូវយើងប្រញាប់រកប្រពន្ធឲ្យវាកុំទុកវានៅចំនោរ
កាលណាវាមានប្រពន្ធទៅក្រែងគ្រាន់បើជាងនេះ ហើយនាំគ្នាទៅកាន់
គ្រូកូលមួយនិយាយដណ្ដឹងកូនក្រមុំ គ្រូកូលនោះគេថា យើងឲ្យមិនបានទេ
ព្រោះកូនអ្នកឯងគេដឹងឮស្គាល់គ្រប់គ្នាថាជាមនុស្សខ្ជិល យើងឲ្យឯណាក៏
បាន ទៅឯណោះគេប្រកែកទៅឯណោះគេប្រកែកគ្រប់ៗគ្នា ចៅកុស
ក៏នៅលើវេហូតអស់១ជីវិត ។ និយាយអំពីចៅសុប្រហ៍ជាក្មេងមានគំនិត
មានព្យាយាមខំរៀនបានប្រឡងជាប់ជាលំដាប់គ្រប់ថ្នាក់ ។ មានប្រាជ្ញា
ឈ្លាសវាងវៃជាងក្មេងឯទៀតៗ គ្រូមានសេចក្ដីស្ញើចសរសើរចៅសុប្រហ៍
សឹងគ្រប់គ្នា ។ កាលជាខាងក្រោយមក ម្ដាយឪពុកចៅសុប្រហ៍ក៏ចូល
អនិច្ចកម្មអស់ទៅ គ្មានបងប្អូននៅកំព្រាម្នាក់ឯង មុះគួរឲ្យករុណាអាសូរ
ចៅសុប្រហ៍តន់តេក វេលាត្រូវទៅសាលា ចៅសុប្រហ៍រាំងច្បារទាក់សោ
រូបហើយទើបបានទៅ ពេលមកពីរៀនវិញ ចៅសុប្រហ៍ថែដំណាំនឹងធ្វើ
បាយស៊ីដោយខ្លួនឯងជាធម្មតា ចៅសុប្រហ៍មានសេចក្ដីលំបាកកាន់តែ
ខ្លាំងឡើងៗ ទាំងនៅរៀនតទៅទៀតមិនបាន ក៏សុំលាគ្រូឈប់រៀន គ្រូ
បង្រៀនក៏សួរថា ហេតុអ្វីបានជាឯងឈប់រៀន យើងមានសេចក្ដីសង្ឃឹម
ចៅសុប្រហ៍ឯងណាស់ថាអំណើះតទៅនឹងបានជានាហ្មឺន១យ៉ាងជាក់ ព្រោះ
យើងឃើញឯងមានប្រាជ្ញាវាងវៃជាងគេឯទៀតទាំងអស់ ចៅសុប្រហ៍

ក៏និយាយសារសព្វដំណឹងត្រង់តាមដំណើររបស់ខ្លួនកំព្រើកំព្រាគ្មានទីពឹង ដោយសព្វគ្រប់ ត្រូវបានស្ដាប់ចៅទុស្សហ៍ថ្លែងសេចក្ដីប្រាប់ហើយក៏ អនុញ្ញាតបើកឲ្យចៅទុស្សហ៍ឈប់តាមបំណង ។

ចៅទុស្សហ៍តាំងពីឈប់រៀនមកឥតមានខ្ជិលច្រអូសពេលណាឡើយ ព្យាយាមថែដំណាំទឹងដើមផ្កាដែលខ្លួនដាំពាសពេញទាំងដីភូមិ សន្សំទ្រព្យទុក មានការតែច្រើនឡើង ដែលបានមកអំពីលក់ផ្លែឈើនិងផ្កានោះឯង ។ លុះផ្លែឈើនិងផ្កានោះមានសម្បូរឡើង ចៅទុស្សហ៍ជួលក្មេងប្រុសម្នាក់ឲ្យរែកផ្លែឈើនិងផ្កាលក់តែរាល់ថ្ងៃ ។

មានសេចក្ដីដំណាលអំពីស្រីម្នាក់ឈ្មោះនាង វិរិយ៍ នាងមានរូបឆោមលោមពណ៌សមរម្យ ទាំងឫកពាកិរិយាមារយាទរបស់នាងសោតទៀតក៏ល្អសុភាពរាបសា គួរជាទីជ្រះថ្លាដល់អ្នកផង នាងបានអាយុ ១៧ ឆ្នាំ ឪពុកស្លាប់ចោលទៅនៅជាមួយនឹងម្ដាយ នាងតែងទិញផ្លែឈើនិងផ្កា អំពីក្មេងដែលរែកទៅលក់នោះសឹងតែរាល់ថ្ងៃ ។ សម័យ ១ នាងកំពុងតែដេកលេងនៅនឹងអង្រឹងក្រោមផ្ទះ បានក្រឡេកឃើញក្មេងនោះរែកផ្លែឈើនិងផ្កាមកដល់ ក៏ហៅក្មេងនោះឲ្យចូលមកនាងទិញរួចហើយ ក៏សួរថា អាខ្មាងឯងនៅផ្ទះឯណាជាកូនអ្នកណា? ក្មេងនោះឆ្លើយថា ឱបង លាក់ ចុំអ៊ី ខ្ញុំនៅស្រុកស្រែចំការទេ តែគេជួលខ្ញុំមកឲ្យនៅជាមួយនឹងគេ ម្ចាស់ផ្ទះនោះឈ្មោះ ទុស្សហ៍ម្ដាយឪពុកស្លាប់អស់ទៅ នៅកំព្រាម្នាក់ឯង

គ្មានបងប្អូន ៗ នាងវីរិយ៍ បានឮក្មេងនោះនិយាយរៀបរាប់ប្រាប់ដូច្នោះ ក៏ក្តួលឡើងក្នុងចិត្តទឹកមិនក្តៅសោះ ហាក់ដូចជាប្តីនឹងប្រពន្ធស្លាប់ស្រឡាញ់រួមសុខទុក្ខជាមួយគ្នាហើយព្រាត់ប្រាសចាកចោលទៅអស់កាលជាយូរអង្វែង នាងវីរិយ៍សួរក្មេងនោះដឹងទីកន្លែងប្រិកល្អកសព្វគ្រប់ហើយ ថ្ងៃក្រោយនាងវីរិយ៍ធ្វើដំណើរដើរចូលទៅផ្ទះចៅឧស្សាហ៍ ហាក់ដូចជានឹងរកទិញផ្លែឈើនិងផ្កា នាងចូលទៅដល់ក្នុងភូមិក្រឡេកទៅឃើញចៅឧស្សាហ៍កំពុងតែថែដំណាំ នាងវីរិយ៍ក៏នឹករឹតតែចាប់ចិត្តស្រឡាញ់ខ្លាំងឡើង ទឹងហាមាត់និយាយស្ទើរពុំកើត ៗ ឯចៅឧស្សាហ៍ក្រឡេកឃើញនាងវីរិយ៍ កំពុងដើរចូលមកក៏សំដែងសេចក្តីគួរសមស្ទុះទៅទទួលរាក់ទាក់ដោយសេចក្តីស្នេហា ហើយក៏សួរថា អ្នកអញ្ជើញមកមានការអ្វី? នាងវីរិយ៍ថា ឱអ្នកបងលាក់បាំងអ្វី ខ្ញុំបានឮគេដំណាលថា នៅផ្ទះអ្នកបងមានដំណាំដាំដុះគ្រប់យ៉ាងមិនមានខ្វះអ្វី បានជាខ្ញុំអត់ទ្រាំមិនបាន ចង់មកមើលលេងដើម្បីកំសាន្តចិត្ត ៗ ចៅឧស្សាហ៍ជាមនុស្សមានគំនិតសុចរិតស្លូតត្រង់ល្អ នាំនាងវីរិយ៍ដើរមើលដំណាំក្នុងភូមិសព្វកន្លែង រៀបរាប់ពីស្នាដៃដែលខ្លួនបាននាំប្រាប់នាងវីរិយ៍ថា :

វីរិយ៍អូនអើយមើលដំណាំ ស្នាដៃបងដាំនៅផែនដី
ដើមខ្លះផ្លែធំខ្លះផ្លែតូច ល្អមើលឥតបីណាមាសបង ៗ
នុះនឹគេហៅថាដើមទៀប ផ្លែដូចដំរៀបក្បែរបង

រយោងរយានដូចគេបង ខ្លួនល្អងនាងមើលគួរប៉ិតនា ។
ឈើខ្លះផ្លែទុំជ្រុះដល់ដី ពួកក្អែកប្រុសស្រីរើសប្រាក់
រេចស្តាយនាំទៅផ្ទះអាត្មា ហើយបរិភោគតាមរៀងកល់ខ្លួន ។
នុះប្អូនមើលចុះសុទ្ធដើមផ្កា ក្រអូបណាស់សាណាមាសស្ងួន
បើបានបេះមកប្រដាប់ខ្លួន មុខគួរឲ្យស្ងួនរួមមេត្រី ។
ដំណាំបងដាំតាំងប៉ុន្មាន ចិត្តបងចង់បានប្អូនពិសី
មកនៅនឹងផ្ទះរួមបេតី គ្រាន់បានស្រស់ដីលេងសប្បាយ ។

នាងវីរយ៍ –

ទបងអើយប្អូនឃើញសព្វហើយ ឥតខ្វះអ្វីឡើយពេញរីកកាយ
ពិតដូចប្អូនឮគេបរិយាយ គួរអាល័យស្តាយដល់បងកាំ ។
កាលដើមកើតទុក្ខមុខក្រៀមស្អុះ គ្មានស្រីបគ្មានស្រស់ស្រួលត្រង់ណា
លេងសើចតែមាត់ចិត្តខ្លោចផ្សា ទុក្ខកងកណែនសើរខ្លាយ ។
ចាល់តែប្រាំនៅផ្ទះពុំបាន កើតចិត្តក្លាហានហាននមើលឆាយ
សំដៅផ្ទះបងឥតកាយខ្មាយ ហាក់ដូចព្រះពាយដាត់មកឯ ។

(នៅមានត)

# ប្រវត្តិសាស្ត្រប្រទេសចិន

## ហ្លួងនិពន្ធមន្ត្រី ញ៉ក-ថែម ប្រែនិងរៀបរៀង

(តមក)

## អំណាចរបស់ហួន

តាំងពីពុទ្ធសករាជ ៩៩០មកនោះ រដ្ឋបាលចិនបានយល់ព្រមឲ្យពួកហួនចំពួកខ្លះ បានសិទ្ធិអំណាចដូចជាចិនដែរ ។ ពួកនេះបានចូលទៅតាំងនៅក្នុង កាន-ស៊ូ, តាន-ស៊ី, និងហ៊េ-ប៉ី, មានមុខក្រសួងតាំងក្នុងទាហានការពាររក្សាអាណាខេត្តចិន ។ ការដែលរដ្ឋបាលចិនបណ្ដោយឲ្យពួកហួនផ្ទង់កំពែងធំចូលមកដូច្នោះ ជាគំនិតគិតខុសយ៉ាងធំក្រៃលែង ព្រោះកាលបើកម្លាំងទាហានថយខ្សោយចុះទៅដូច្នោះ ពួកហួនក៏សំនោះក៏កម្រើកឡើង ក្នុងឆ្នាំពុទ្ធសករាជ ៨៤៨ មានហួនមួយពួក បានតាំងខ្លួនមានអំណាចក្នុងខេត្តតាន-ស៊ី មានមេទ័ពឈ្មោះលៀវ-សុង បានរុកកន្ទ្រានចូលទៅក្នុងខេត្តហូ-ណាន កាលពីឆ្នាំពុទ្ធសករាជ ៨៥៤ ហើយបានលើកទៅវាយយកស្រុកលោ-យ៉ាំងបានទៀត ។ ឯមហាក្សត្រចិនក្នុងវេលានោះទ្រង់ព្រះនាមថា ព្រះបាទហួយ-ទី ក៏ត្រូវពួកហួនចាប់យកទ្រង់ទៅបាន កាលចូលស្រុកលោ-យ៉ាំងហើយ លៀវ-សុងក៏ត្រឡប់ចូលមកស្រុកតាន-ស៊ីវិញ នាំយកព្រះមហាក្សត្រចិនដែលចាប់បានទៅធ្វើគតបង់ទៅកាលពីពុទ្ធសករាជ ៨៥៧ ។ តមក ៣ ឆ្នាំទៀត លៀវ-សុង ក៏រុកកន្ទ្រានចូលទៅដល់ស្រុកស៊ុ-អាន ដែលមានព្រះមហាក្សត្រចិន

ទ្រង់ព្រះនាមថា ព្រះបាទម៉េង.ទី ទ្រង់គ្រប់គ្រងរាជសម្បត្តិជាជំណាតមកពី ព្រះបាទហ្គូយ.ទី ដែលត្រូវពួកហ្វូនផ្ដួលទៅហើយនោះ ។ ពួកហ្វូនបានលើកទ័ពទៅបុកស្រុកស៊ី-អាំនជាវេលាយូរ តែនៅទីបំផុតក៏បានទៅគណ្ដាប់ដៃរបស់ពួកហ្វូនទៀត ។

កាលបើកើតមហាភ័យដូច្នេះហើយ រាជវង្សស៊ិនក៏ថយចេញពីស្រុកណោ-យ៉ាំង និង ស៊ី-អាំន ទៅតាំងក្រុងឯស្រុកណាន-គិង (ណាំ-កាំង) មានទំនងដូចជាពួកកេមាំងបានផ្លាស់ពីក្រុងរោម ទៅតាំងក្រុងនៅកុង-ស្តង់ទីនោប្លឺ ។ ឯអាណាខេត្តចិននៅភាគខាងជើង ក៏ធ្លាក់ទៅនៅក្នុងអំណាចពួកហ្វូនទាំងអស់ ។

## វគ្គទី ៣

## អាណាចក្រចិនភាគខាងត្បូង

## អំណាចរបស់ពួកហ្វូន

កាលពួកចិនត្រូវពួកហ្វូនបណ្ដេញឲ្យថយចេញទៅទិសខាងត្បូង ផុតពីខេត្តដែនដៃទន្លេសំខាន់ ២ គឺៈហ្វាំង-ហូ និងយ៉ាំង-សេ ហើយអាណា-ចក្ររបស់រាជវង្សស៊ិន ក៏បានតាំងនៅជាឥស្សរៈតមកទៀតជាវេលាមួយសតវត្សរ៍គឺតាំងពីពុទ្ធសករាជ៨៦០ ដល់ពុទ្ធសករាជ៩៦៣ ហៅថា អាណាចក្រភាគខាងត្បូង តែអាណាចក្រនេះគ្រាន់តែជាអាណាចក្រ

តូចៗ មិនសូវមានសេចក្ដីចំរើន តាំងមានសេចក្ដីខ្សត់ក្រជាច្រើនហើយ ខ្សោយកំឡាំងការទ្រាំទ្រផង ។ ព្រះមហាក្សត្រចិនគង់ក្នុងព្រះរាជវាំងស្រុក ណាន-គីង (ណាំ-កាំង) ហោមរោមដោយពួកស្រីស្នំស្រីគ្នារ និងពួកខន្ទី (ពួកប្រុសកម្រៀវ) សឹងតែក្អកស្អប់ស្អល់រកយសប្បាយដោយតាមតណ្ហា មិនសូវគិតគូរដល់ស្រុកទេសទៀយ មានចំនួនដូចក្រុងពេចក្នុងសម័យ ដែលអស់អំណាច ៗ ប៉ុន្តែទុកជាក្រដៃស្រុង ថយខ្សោយអំណាចសាប សូន្យទៅដល់ម៉្លោះក៏ដោយ គង់នៅមានគេក្ដិវៃណលមួយដែលមិនបាន សាបសូន្យទៅផងទៀយ គឺព្រះរាជពិធីងគិត្តិយសរបស់មហាក្សត្រចិន នៅគង់ទ្រង់ដដែលមិនបានបាត់បង់ទៅផងទៀយ ។ះ

ចំណែកនៅភាគផែនដីចិនទិសខាងជើងនោះ ទុកជាពួកហ្វូនបាន ចូលមកគ្រប់គ្រង ផងទ្វេហ្វាង ហូទឹងយ៉ាង-សេ ហើយក៏ដោយ ការ្យៈ ធម៌របស់ជាតិចិនសុទ្ធក៏គង់ទ្រង់នៅមិនបង់សាបសូន្យទៅទេ ៗ ខនេះ ឯងជាលក្ខណៈដែលប្លែកប្លែក រាជ្យក្រុងពេចនឹងក្រុងចិនពោលគឺ ក្រុងពេចនោះ កាលត្រូវពួកមនុស្សព្រៃលុកលុយដល់ក្រុងហើយ ក្រុង ពេចក៏អស់អំណាចសាបសូន្យទៅដោយងាប់ហើយ តែស្រុកចិនមិន បានសាបសូន្យទៅដូចនោះទេ គឺថាមិនតាចតែបែបលក្ខណៈរបស់ចិនឲ្យប្រែ ប្រែលទៅជាយ៉ាងដទៃទៀតបានឡើយ ៗ គមកក្នុងរាជ្យពុទ្ធសករាជ៩០០ ឆ្នាំ ពួកនៅផែនដីភាគខាងជើងគឺពួកហ្វូននិងពួកមញ្ចូ នាំគ្នារុកាន

ទន្ទ្រានចូលមកផែនដីភាគខាងត្បូងទៀត តែរាជអាណាចក្រចិន ដែលតាំងទីក្រុងនៅណាន-គិងក៏គង់តាំងខ្លួននៅបានដដែល ។

ក្នុងសម័យពុទ្ធសករាជ ៩០០ឆ្នាំនោះ នៅភាគខាងជើងប្រទេសចិន សឹងពាសពេញទៅដោយពួកមនុស្សច្រើនពួកច្រើនសែស ច្រើនជាតិ នាំគ្នាច្បាំងដណ្ដើមផែនដីគ្នាទៅវិញទៅមក ។ ការដែលពួកហ្វូនចូលមកវាយយកស្រុកឡោ-យ៉ាំង កាលពីពុទ្ធសករាជ ៨៥៤ ក្ដី ការដែលវាយយកស្រុកស៊ី-អាន កាលពី ៣ ឆ្នាំតមកទៀតក្ដី សឹងជាគ្រឿងសញ្ញាប្រាប់ថានឹងមានចម្បាំងលុកលុយយ៉ាងធំហូតមកដល់សម័យដែលមនុស្សមួយពួកហៅថា តូ-ប: លុកលុយចូលមកស្រុកចិនទៀត ។

ពួកមនុស្សព្រៃ ដែលបានចូលមកតាំងនៅក្នុងរាជអាណាចក្រចិនជាដំបូងនោះ គឺពួកហ្វូនមួយពួកដែលហៅថា ហ្វូន-ហៅ នាយករបស់ពួកនេះឈ្មោះលៀវ-សុង ។ អំណើះកាលតមក ទើបមានពួកហ្វូនជាច្រើនពួកនាំគ្នាលុកលុយចូលមកទៀត ក្នុងរវាង៥០ឆ្នាំ ។ ពួកហ្វូនបានចូលមកនៅស្រុកប៉េ-ចិលី, ចាន-ស៊ី និងចេន-ស៊ីនិងទីដទៃ ។ នៅផែនដីចិនភាគខាងជើង ។ តមកនៅក្នុងរវាងពុទ្ធសករាជ ៨០០ឆ្នាំ ទើបអំណាចហ្វូនវិនាសបង់ទៅដោយមានជនមួយពួកហៅថា សាំន-ពី ជាពូជពួកមញ្ជូ មានលំនៅដើមនៅស្រុក មុក-ដេន បែងចេញជា ៣ ពួក គឺហៅថា មូ-យ៉ង មួយពួក, តេ-យូគេន មួយពួក, តូ-ប:

មួយពួក, ទាំង ៣ ពួកនេះបានធ្វើការយ៉ាងសំខាន់បំផុត ក្នុងពង្សាវតារនៃបូព៌ាប្រទេស ។

ពួកមូ-យ៉ុងបានបំផ្លាញអាណាចក្ររបស់ពួកហ៊ូន-ចៅបានសម្រេច កាលពីពុទ្ធសករាជ ៨៩៥ ហើយបានគ្រប់គ្រងអាណាខេត្តភាគខាងជើង ជាវេលា ២៥ឆ្នាំ ។ ក្នុងឆ្នាំពុទ្ធសករាជ ៩១៨ ពួកមូ-យ៉ុងត្រឡប់ជាត្រូវពួកទាហានចាស់របស់ហ៊ូន-ចៅវាយខ្ចាត់ខ្ចាយអស់ទៅ មេទ័ពហ៊ូននេះឈ្មោះហ្វូ-កៀន បានតាំងអាណាចក្រថ្មីឡើងនៅស្រុកចេន-ស៊ី មានស្រុកស៊ី-អាំនជាទីក្រុង ។ តាំងពីនោះមក ពួកមូ-យ៉ុងក៏ថយរោយអំណាចទៅ នៅសល់តែខេត្តដែនត្រឹមប៉េ-ចិលីនិងចាន-តុង តាំងរាជ-វង្សក្សត្រឡើងហៅថា ព្រះមហាក្សត្រពងវង្សយេន បានគ្រប់គ្រងខេត្តដែនទាំងនោះរហូតដល់ឆ្នាំពុទ្ធសករាជ ១,០០០ ។ ឯពួកតេ-យូវេ ដែលមានឈ្មោះម្យ៉ាងទៀតថា យេស៊ូ-យ៉ានឬយួនយួន បានតាំងទី-កន្លែងនៅក្នុងស្រុកម៉ុងហ្គោលី មានអាណាខេត្តធំទូលាយ តាំងពីពុទ្ធសករាជ ៩៤៥ ដល់ពុទ្ធសករាជ ១០៩៥ ហើយគេយល់ថាពួកនេះឯងដែលច្បាំងរុកបណ្តេញពួកហ៊ូនមួយពួកឲ្យថយចូលទៅក្នុងទ្វីបអឺរ៉ុប ដែលមានអត្តិលាជាប្រមុខ ដូចមានសេចក្តីសរសេរទៅខាងមុខ ។

ចំណែកឯពួកតូ-បះនោះ ជាពូជពង្សវង្សត្រកូលមញ្ជូដែរបានលើកទៅតាំងនៅភាគខាងជើងដែនចេន-ស៊ី តាំងពីពុទ្ធសករាជជាង ៨០០ ឆ្នាំ

មក ព្រះមហាក្សត្រត្រកូលជ្វារបស់ជនពួកនេះ មានឈ្មោះដូចជាព្រះមហាក្សត្រចិនដែរ គឺហៅជាពងវង្សវេ-អ៊ុំ មានទីក្រុងដំបូងតាំងនៅឯគាំ-តុង ។ ពួកគូ-ប:នេះជាន់ដើមចិនប្រកាន់ថាជាពួកមនុស្សព្រៃដែរ តែជាពួកដែលបានទទួលយកអារ្យធម៌និងបែបផែនរបស់ចិន ទៅទុករក្សាបានច្រើនបំផុត ឯពួកហ្វូនឬពួកឯទៀតៗ ច្រើនតែជាអ្នកបំផ្លាញអារ្យធម៌របស់ចិនឲ្យវិនាសបាត់បង់ទៅ ។ ចំណែកខាងពួកគូ-ប:មិនធ្វើដូច្នោះទេ ត្រឡប់ជាថែរក្សាសេចក្ដីចំរើន ដែលចិនបានធ្វើទុកនោះឲ្យគង់វង្សនៅជាទីពឹងទើបពួកនេះមានលក្ខណ:ជាចិនកាន់តែច្រើនឡើង ហើយបានកំចាត់ពួកមនុស្សព្រៃឯទៀតឲ្យខ្ចាត់ខ្ចាយអស់ទៅ តាំងមានបំណងនឹងរួបរួមអាណាចក្រចិនជាថ្មីឡើងវិញផង ។ ចំណែកខាងកងសំណាក់ចិនស្រុកណាន-គីងនោះកំពុងអាប់ឱនជាភាគសិស្រុកមិនឡើងឡើយ ពោលគឺកើតក្បត់បះបោរកាប់សម្លាប់គ្នាឥតស្រាកស្រាន្ត ។ ពួកចិនក្នុងកងវង្សស៊ុន ក៏កាន់តែរៀវរោយបាត់ពន្លឺស្ទើរតិចម្ដងៗជានិច្ច ឯពួកគូ-ប:នៅទិសខាងជើងក៏កាន់តែរឹងប៉ឹងខ្លាំងពូកែឡើង ព្រះមហាក្សត្រគូ-ប:អង្គដំបូង ទ្រង់ព្រះនាម កៀវប្ដូគូ-ប:កៀវ ដែលបានគ្រប់គ្រងរាជសម្បត្តិក្នុងរវាងពុទ្ធសករាជ ៩២៩ ដល់ពុទ្ធសករាជ ៩៥២ ។ នៅក្នុងឆ្នាំព្រះពុទ្ធសករាជ ៩២៩ នោះ ជាឆ្នាំចំរើនរុងរឿងរបស់ពងវង្សគូ-ប: ព្រះបាទគូ-ប:កៀវនោះ សូម្បីពួកចិនដែលជាសត្រូវក៏មានសេចក្ដីសរសើរជាច្រើន

ពិតមែនជាពួកមនុស្សព្រៃ តែមានសតិបញ្ញាឆ្លៀវឆ្លាតក៏ទៃជាចំណាប់ពួកមនុស្សបែបនេះបានដោយកម្រណាស់ ។ កាលទ្រង់បានតាំងឡាក់-ឋានក្នុងខេត្តដែនរបស់ចិនសុទ្ធហើយ ទើបទ្រង់បែរទៅច្បាំងតស៊ូនឹងពួកមនុស្សព្រៃវិញ ។ ព្រះមហាក្សត្រគ្រងរាជ្យជាលំដាប់តមក ទ្រង់ព្រះនាម សេឃុតូបៈសេ ទ្រង់គ្រប់គ្រងរាជសម្បត្តិក្នុងរវាងឆ្នាំពុទ្ធសករាជ ៩៥២ ដល់ពុទ្ធសករាជ ៩៦៦ ក៏បានរៀបចំផ្ញើប្រសាស្ន៍ទៅនាបាយមានទំនងដូចជាព្រះបាទតូ-បៈកៀវដែរ គឺច្បាំងលុកលុយចូលទៅក្នុងស្រុកម៉ុងក្លី ហើយបានប្រាបប្រាមផ្ដួលពួកកេ-យូគេនបានសម្រេច ចំណែកខាងស្រុកចិនបានខេត្តដែនស្រុកលោ-យ៉ាំងនឹងហ៊ូ-ណាន មកបញ្ចូលក្នុងរាជអា-ណាចក្ររបស់ទ្រង់ថែមទៀត ។ ព្រះមហាក្សត្រគ្រងរាជ្យជាតំណតមកទ្រង់ព្រះនាមតូ-បៈហ៊ៅ ឡើងសោយរាជសម្បត្តិតាំងពីឆ្នាំពុទ្ធសករាជ ៩៦៧ ដល់ពុទ្ធសករាជ ៩៩៥ ទ្រង់ពង្រីកអាណាខេត្តវាយបានស្រុកចេន-ស៊ីមកទៀត ទើបអាណាខេត្តចិនទិសខាងជើងទាំងអស់ បានធ្លាក់ទៅនៅក្រោមអំណាចរាជវង្សតូ-បៈ ហើយនៅក្នុងឆ្នាំពុទ្ធសករាជ១០៣៨ មានព្រះមហាក្សត្រអង្គមួយទ្រង់ព្រះនាមតូ-បៈហាន បានផ្លាស់ទីក្រុងពីស្រុកប៉ិង-ជិង ក្នុងខេត្តចេន-ស៊ី ដែលជាទីក្រុងចាស់របស់រាជវង្សតូ-បៈ ទៅនៅឯលោ-យ៉ាំងក្នុងខេត្តហូ-ណានវិញ ដែលជាទីក្រុងចាស់របស់ពួកចិនសុទ្ធ ។

(មានត)

## ឃុនឧត្តមប្រីជា ចាប-ពិន

រៀបរៀង (តមក)

### ៤៦ - ចង់ស្រួចដូចបន្លា, ត្រូវឧស្សាហ៍ដុសដែកដុល

ពាក្យនេះបុរាណប្រដៅថា

អ្នកណាចង់ស្រួចដូចបន្លា   គឺថាបេះដូងមោះមុតច្រើន ។
អ្នកនោះត្រូវញ៉ាំងក្តីឧស្សាហ៍   ឲ្យកើតកៀវក្លាដប់ម៉ឺន
រឿយ ៗ ពល់កិច្ចទោះតិចច្រើន   បង្កើនកុំបីឲ្យរេក ។
តាំងចិត្តឲ្យជាប់នៅជានិច្ច   ម្តង ៗ បន្តិចដោយខ្មីឃ្មាត
កុំដាច់ស្រយាលឃ្លាលឃ្លាត   រវាតបោលកិច្ចដែលសិក្សា ។
ផលនៃព្យាយាមដ៏អង់អាច   ឲ្យបានជាប្រាជ្ញមានប្រាជ្ញា
ស្រួចស្រាល់អាចដោះអាថ៌ប្រស្នា   មុតដូចបន្លាឬដូចម្ជុល ។
ដូចអ្នកចង់ស្រួចដូចបន្លា   ត្រូវតែឧស្សាហ៍ដុសដែកដុល
ឲ្យបានស្រួចស្រាល់ដូចចុងម្ជុល   ទើបនឹងដាក់ដុលបានដោយងាយ ។

### ៤៧ - ចាក់ប្រកមិនសំឡឹងក្រោយ

សុភាសិតនេះលោកប្រឌិត

តាមហេតុដែលធ្លាប់មានមកពិត   ធៀបនឹងទឹកចិត្តមនុស្សទាំងឡាយ ។
មនុស្សខ្លះចាប់ផ្តើមធ្វើការអ្វី   ក៏ធ្វើហើយមិនខ្វល់ខ្វាយ
មិនមើលផ្ទឹងក្រោយឲ្យវែងឆ្ងាយ   គ្មានកេឧបាយនៃប្រាជ្ញា ។

មនុស្សខ្វះសិក្សាវិជ្ជាអ្វី    មិនមានសេចក្ដីពិចារណា
ឲ្យដឹងគោលសូត្រដែលសិក្សា    នោះថាអាទិ៍ផលដូចម្ដេចទៅ ។
បើចេះតែរៀនឥតបើគិត    ឥតយោលគំនិតឲ្យឃើញជ្រៅ
ឥតរិះឲ្យដឹងរសជាតិជ្រៅ    តោះរៀនចេះទៅក៏ទន់ខ្សោយ ។
យ៉ាងនេះបោកណាឲ្យឈ្មោះថា    "ដូចតាក់ប្រាំមិនមើលជ្រោយ"
អានិសង្សទាំងនោះក៏មិនឲ្យ    អំណោយប្រសើរគ្រាន់បើឡើយ ។

## ៤៨- ចាញ់ចាញជាព្រះ, ឈ្នះចាញជាមារ

ពាក្យនេះចាស់ៗពីបុរាណ

ភ្ជាប់ពោលនិយាយសឹងគ្រប់ប្រាណ ដោយបានស្ដាប់ឮតៗគ្នា ។
ជាពាក្យដែលពោលបន្ទន់ចិត្ត    បន្ទំគំនិតអ្នកល្អជា
កុំពេលមានរឿងអ្វីនឹងគ្នា    កុំឲ្យគ្រោធាឲ្យខំអត់ ។
មនុស្សណាដែលមានចិត្តកំណាច    ឥតកោតឥតខ្លាចការឥតបទ
ឥតគិតបាបបុណ្យគុណពៃរ៍    ឥតអត់ឥតអោនឲ្យអ្នកណា ។
មនុស្សនោះអ្នកប្រាជ្ញលោកអាចហៅ    ថាមនុស្សចិត្តខ្មៅដូចមារ.
មនុស្សណាចិត្តស្លូតទន់ល្អជា    មនុស្សនោះលោកថាចិត្តជាព្រះ ។
ធម្មតាអ្នកសាងជាព្រះពុទ្ធ    មានចិត្តមោះមុតជះស្រឡះ
ខន្តីអំណត់មិនខ្មោះមានះ    មិនលះព្រះធម៌ដ៏កល្យាណ ។
កាលនៅជាព្រះពោធិសត្វ    ចិត្តលោកល្អក្លាត់ឥតថ្លឹមបាន

បំពេញបារមីដ៏ក្លាហាន　　ដើម្បីឲ្យបានជាព្រះពុទ្ធ ។
ក្នុងពេលដែលតាំងមហាប្រាថ្នា　　ច្រើនមានមនុស្សកាចមកគាបត្បុត
ឲ្យបានលំបាកជាបំផុត　　តែអង្គពង្សពុទ្ធមិនតបត ។
គិតតែចំរើនអត់សង្កត់　　ខន្តីអំណត់ឲ្យបានល្អ
ធ្វើទឹកព្រះទ័យឲ្យថ្លាស　　ចំកចំសានយ៉ាងក្លាហាន ។
លុះពេញកំណត់ទ្រង់បានត្រាស់　　ដឹងច្បាស់ព្រះធម៌ពោធិញ្ញាណ
បានជាព្រះពុទ្ធដ៏ថ្កើងថ្កាន　　ឥតមានអ្នកណាប្រៀបផ្ទឹមដល់ ។
ចំណែកខាងមនុស្សពាលទ្រង់　　ដែលធ្វើព្រះអង្គឲ្យកង្វល់
ដោយចិត្តកំណាចបាបអកុសល　　ពុះដល់បំផុតក៏វេទនា ។
អ្នកស្លូតដែលពាញ់បានជាព្រះ　　អ្នកកាចដែលឈ្មោះជាមារ
ហេតុនោះព្រោកណាលោកពោលថា　　ដូចមាតិកាខាងដើមនោះ ។

## ៤៩ – ចានមួយរាវលែងអីរណ្តំគ្នា

ពាក្យនេះជាពាក្យបន្ទូរចិត្ត

អ្នកមានទុក្ខព្រួយឲ្យថយគិត　　ព្រោះវានពិចិត្រតាមធម្មតា ។
គឺលោកសំដែងពីបងប្អូន　　ឬមួយក៏កូននឹងមាតា
បិតាស្វាមីនឹងភរិយា　　ដែលនៅរួមគ្នាក្នុង ១ ផ្ទះ ។
ជាលែងអីមានស្កៀរម្ចាស់　　រវេងអីមានទាស់ទែងគ្នាខ្លះ
ដូចចាន ១ រាវលែងអីប៉ះ　　ប្រទះរណ្តំខ្លះពុំមាន ។

ជុំថ្លៃបងប្អូនប្រមាត បិតាទាស់គ្នាមិនកុំខាន
គង់ជាវិញឆាប់ដោយស្មោះស្មាន ព្រោះសុទ្ធតែមានចិត្តមេត្តា ៗ
ហេតុនេះលោកពោលបន្ទូរចិត្ត ឲ្យគិតសន្តោសតាមធម្មតា
ថា "ចាន ៤ រាវគង់ប៉ះពារ រណ្ដំគ្នាខ្លះពុំខាន ៗ

៥០ - ចាប់នេះចាប់នោះ មិនឈ្មោះត្រង់ណា

សុភាសិតនេះលោកពោលទំប់.

ចិត្តមនុស្សអ្នកធ្វើការមិនឈប់ តែមិនប្រាជ្ញព្រោះប្រាជ្ញ ៗ
ឲ្យស្រេចមួយៗ ដោយគ្រប់គ្រាន់ ធ្វើនេះមិនទាន់បានហ្មត់ចត់
ទៅធ្វើនោះទៀតជាប្រចបច ឥតមានកំណត់ណាមួយឡើយ ៗ
ទោះរៀនចំណេះវិជ្ជាអ្វី មិនខំឃ្មាតខ្មីឲ្យស្រេចហើយ
ចាប់នេះចាប់នោះថែបពោះពើយ សើយៗ ធើយៗ មិនរកវី ៗ
គ្មានចប់វិជ្ជាណាមួយសោះ លោកផ្ដោះបញ្ញល ៗ គ្រប់រឿង
ដោយចិត្តឡេះឡោះមិនសម្ដី ផលទីបំផុតក៏ខូចខាត ៗ
ដូចមាននិទានលោកប្រាប់ ថាមានមាណពឈ្មោះ "នាគនាថ"
ថ្ងៃមួយគាត់ខំដើរសន្ទាច ក្នុងព្រៃស្បាតជាផ្លូវឆ្ងាយ ៗ
លុះពេលថ្ងៃត្រង់កន្ទុំព្រៃ ជាពេលស្រេកទឹកឃ្លានបាយ
គាត់ឈោងចាប់បេះបានផ្លែស្វាយ មានចិត្តស្រស់ស្រាយហួសវិស័យៗ
ហើយមើលទៅឃើញផ្លែព្រះទៀត ចិកធៀតបង់បានឲ្យច្រើនក្រៃ

ក៏យកផ្លែស្វាយនៅនឹងដៃ　　តែវះបោលទៅផ្លែ ១ ទៀត ។
តែបោលមិនត្រូវផ្លែក្រោយសោះ　　ផ្លែស្វាយមុននោះក៏បង់សៀត
ទោះបីសង្វាតឧហាតទៀត　　យកអ៊ីបោលទៀតក៏លែងបាន ។
ផ្លែស្វាយខាងក្រោយមិនបានសោះ　　ផ្លែស្វាយមុននោះក៏ខូចខាន
ពុំបានសម្រេចដូចប្រណិធាន　　នាំឲ្យតែបានទុក្ខល្ហាក់ល្ហើក ។
បើសព្យាស្រ័យស៊ីស្វាយមុន　　គ្រាន់បានជាគុណឆ្ងាញ់មួយលើក
បានមានតម្កាំងទៅមួយល្បើក　　សឹមបើកចង់បានទៀតទើបជា ។
រឿងនេះជារឿងពីអតីត　　ប្រាជ្ញការសិតដែលប្រាជ្ញថា
"ចាប់នេះចាប់នោះមិនត្រូវណា."　　អ្នកមានប្រាជ្ញាគួរចងចាំ ។

## ៥១— ចិត្តជាទេវទត្ត, មាត់ជាទេវតា

សុភាសិតនេះលោកប្រៀបប្រាយ

ពីចិត្តគំនិតមនុស្សទាំងឡាយ　　ដែលក្លាយមិនល្អដូចវាចា ។
ធៀបចិត្តអាក្រក់នៃទេវទត្ត　　ធៀបមាត់អាក្រក់នៃទេវតា
ថាមនុស្សខ្លះល្អតាមតណ្ហា　　ប្រាជ្ញាអាក្រក់ជាទុច្ចរិត ។
មានពុតកំបាំងក្នុងចិត្តា　　តែមានវាចាល្អពិចិត្រ
អ្នកណាមិនដឹងថាល្អពិត　　តែមានគំនិតអាក្រក់សោះ ។
មនុស្សខ្លះមានចិត្តល្អណាស់ណា　　តែមានវាចាអសុរោះ
អ្នកណាមិនដឹងថាដូច្នោះ　　ថាមិនល្អសោះព្រោះវាចា ។

ហេតុនេះអ្នកប្រាជ្ញចេះដឹងពិត   លោកស្គាល់ទឹកចិត្តទើបពោលថា
"ចិត្តជាទេវតា, មាត់-ទេវតា"   ឲ្យយើងកល់គ្នាចេះប្រយ័ត្ន ។

៥២- ចុះទូកកុំឲ្យចុះកាឡៃ, នៅព្រៃកុំឲ្យចាំជម្រំ

ពាក្យនេះបុរាណពោលពន្យល់

ឲ្យយើងអង់អាចប្រាជ្ញប្រតិពល   ស្គាល់ការរវល់ផងនានា ។
អ្នកកាន់កៃទូកតែងនឿយ   រឿយៗមិនជាប់កល់វេលា.
អ្នកចាំជម្រំក៏ដូចគ្នា   ព្រោះខ្លួនជានាអ្នកដទៃ ។
ហេតុនេះបុរាណបានពោលមក   ឲ្យយើងរិះរកប្តិតតៃ
កែខ្លួនកុំឲ្យមានមោះមៃ   ព្រោះអ្នកដទៃគេផ្ដុតលើ ។

៥៣- ចូលស្ទឹងតាមបត់, ចូលស្រុកតាមប្រទេស

ពាក្យនេះជាពាក្យពោលសម្រប

ឲ្យយើងជាមនុស្សចេះកែបកប   សម្របខ្លួនប្រាណតាមអ្នកផង ។
ដូចយើងចូលទៅនៅស្រុកគេ   ត្រូវគិតរិះរកកុំឲ្យឆ្គង
ត្រូវចេះបត់បែនតាមគន្លង   ដែលពួកអ្នកផងធ្លាប់ធ្វើមក ។
កុំនាំងពីបែបផែនគេពេក   ត្រូវឡេកមើលគេហើយលៃលក
ដូចទូកចូលស្ទឹងត្រូវរិះរក   បត់យកឲ្យត្រូវតាមបត់ ។
សូម្បីចូលស្រុកគេមួយពេល   ត្រូវមើលដើងកេលឲ្យហ្មត់ចត់
សម្រេចសម្រួលស្រួលតាមផ្នត់   ដែលគេកំណត់នៅក្នុងស្រុក ។

ប៉ុន្តែឲ្យត្រូវទីនច្បាប់ផង   កុំឲ្យសៅហ្មងកើតអុកឡុក
ត្រង់ណាមិនល្អគួរលើកទុក   ខំតាមគ្រប់មុខកុំស្រួលវែរ ។

### ៥៤- ចេះកាប់ពពក, ជីកអាចម៍ជន្លេន

សុភាសិតនេះពោលចំណេះ

ដំនៀលពួកជនណាដែលចេះ   ចំណេះគុណធម៌ល្អណាស់ណា ។
តែមិនប្រព្រឹត្តតាមចំណេះ   ដែលខ្លួនបានចេះបានសិក្សា
ធ្វើបាបដោយកាយវាចា   បានទុក្ខទោសាឃើញទាន់ហន់ ។
ព្រះធម៌ដែលជនបានរៀនយក   ប្រៀបដូចពពកខ្ពស់ពេកពន់
ជនណាបានរៀនច្រើនលើសលន់   លោកប្រៀបដូចជនកប់ពពក ។
ប៉ុន្តែជននោះមិនប្រព្រឹត្ត   តាមធម៌ល្អពិតដែលរៀនយក
លោកណាហៅ "ចេះកប់ពពក   ត្រឡប់ជាជីកអាចម៍ជន្លេន" ។

### ៥៥.- ចេះដប់មិនស្មើប្រសប់មួយ

សុភាសិតនេះពោលសរសើរ

តាមដោយនូវភាពទីដំណើរ   ដែលដើរទៅស្រួលព្រោះប្រាជ្ញា ។
ចំណេះទាំងពួងលោកលើកទុក   ជាមុខជាបាតពេកណាស់ណា
ប៉ុន្តែអ្នករៀនមានប្លែកគ្នា   តាមភាពវាសនារបស់ខ្លួន ។
ដូច្នេះអ្នកខ្លះរៀនចំណេះ   បានចេះដូចគេគ្រប់ចំនួន
ប៉ុន្តែគេគ្រាន់បើជាងខ្លួន   មាំមួនដោយគេប៉ិនប្រសប់ ។

គេមានយោបល់មានឧបាយ កែកុននាយកាយកាយត្រឡប់
ធ្វើការបានស្អាតល្អតាំងគ្រប់ ឆាប់ជប់ឆាប់កើតមិនបាច់ព្រួយ ។
ហេតុនេះលោកថា "ចេះស៊ើ ៗ ផល់ផប់មិនស្មើប្រសប់មួយ"
អ្នកចេះគួរកប្រសប់ផ្ទុយ លើកស្ទួយចំណេះឲ្យគ្រាន់ឡើង ។

## ៥៦ – ចេះពីរៀន, មានពីរក, ក្រពីខ្ជិល

ពាក្យនេះជាពាក្យសុភាសិត

អ្នកប្រាជ្ញជាន់ចាស់លោកប្រឹក នាំចិត្តកូនចៅឲ្យស្រះគ្នា ។
ខំរៀនចំណេះរកធនធាន ឲ្យចេះឲ្យមានទ្រព្យវិជ្ជា
ដើម្បីចំរើនគុណភាព គ្រាន់ជាការស្ទួយប្រទេសជាតិ ។
ដ្បិតស្រុកដែលមានសុខសេរី ថ្កើនថ្កានឥតបីយ៉ាងសីហនាទ
ដោយសារអ្នកស្រុកខំខ្មីឃ្មាត ឥតខានរកតាំងអស់គ្នា ។
អ្នកណាឧស្សាហ៍ខំខ្នះខ្នែង ប្រឹងប្រែងគ្រប់ប្រាណគ្មានរួញរា
ខំរៀនខំរិះរកទ្រព្យា អ្នកនោះមុខជាមានទ្រព្យច្រើន ។
អ្នកណាមិនរៀនសូត្រចំណេះ មុខជាមិនចេះមិនចំរើន
អ្នកណាមិនខំគិតរកវេន ទីងបានទ្រព្យច្រើនមកពីណា ។
ការខ្ជិលជាការមិនមែនល្អ នាំឲ្យពាល់គ្រប់ប្រាជ្ញា
ហេតុនេះព្រោកណាលោកពោលថា ដូចបទមាតិកាដើមនុះឯង ។

(មានត)

## វណ្ណកថា

## នារាយណ៍ ទសាវតារ

ឧកញ៉ាទេពពិទូរ ក្រសេម រៀបរៀង

(តមក)

សិល្បសាស្រ្តដល់ក្សត្រ ហើយថែកទីលំនៅ គឺព្រះឥសូរនិមិត្តភ្នំកៃលាស ជាទីលំនៅ, ព្រះនារាយណ៍ស្ថិតនៅក្បែរសមុទ្រ ព្រហ្មលោកនោះឲ្យជាទីស្ថិតនៃព្រហ្មជាតា ។

មួយទៀត អ្នកប្រាជ្ញគឺរុបពោលថា កាលព្រះវិស្ណុបានជួយព្រះមនុរូបអំពីទឹកលិចលោកហើយ កើតមាននាងបញ្ចកល្យាណីរូបកន្ស្រលង់សឹងជាទីត្រេកចិត្តរបស់ព្រះអស្វិន[១] ទូទៅ តែនាងនោះគ្មានចិត្តស្នេហា ទើបបដិសេធថានាងជារបស់អ្នកដែលបានសាងនាង ទើបលើលាមកគាល់ព្រះមនុ ទ្រង់ពេញចិត្តក្នុងលំអរបស់នាងយ៉ាងក្រៃពេក នាងគេចមុខបែរមើលទៅព្រៃព្រឹក្សា ដើម្បីរំសាយសេចក្ដីអៀនអន់ក្នុងទីបំផុតឥដា (ida) បានក្លាយជានាងពពែ ព្រះមនុក៏ក្លាយជាពពែឈ្មោលហើយក្លាយខ្លួនជាសត្វប្រភេទផ្សេងៗ រួមសេជាមួយគ្នាតមក ទើបកើតជាសត្វលោកមានប្រភេទផ្សេងៗ ឡើង ។

---

១ អស្វិនក្នុងទីនេះជាគណៈទេពមួយពួក, ក្នុងគម្ពីរមហាភារតថា ទេវភ្លោះ ១ អង្គនាមព្រះនាសត្យអស្វិន ១ អង្គទៀតនាមព្រះទស្រអស្វិន ជាឱរសព្រះសុរិយាទិត្យនឹងនាងអស្វិនី ។

ព្រះមនូស្វយម្ភូវៈ ជាអ្នកទទួលភារៈសាងមនុស្ស ទើបបានសាង ប្រជាបតី ១០រូប ដើម្បីជាមហាជនករបស់មនុស្សតមក ព្រះមនូមានកំណត់កើតក្នុងលោក ១៤ អង្គ ជាធំក្នុងលោក ១ មានវារៈ[1] គិតជៀបនឹងឆ្នាំមនុស្ស ៤,៣២០,០០០

ព្រះមនូវៃវស្វតៈ មានឧរសនាមថា ឥក្ខ្វាកុ បឋមក្សត្រសុរិយវង្ស គ្រប់គ្រងនគរស្រីអយុធ្យា មានទាក់ទងនឹងរាមបទ្រាវតារក្នុងគ្រាតទៅទៀតផង ។

ក្នុងរឿងនារាយណ៍សិបប៉ាង ច្បាប់ហោរាព្រះសមុត (របស់សៀម) ពោលរឿងនៃត្រីមច្ឆា ដោយហេតុព្រះព្រហ្មណាគាបានពរអំពីព្រះឥសូរ ដែលទ្រង់ប្រទានឲ្យជាធំក្នុងព្រហ្មលោក ព្រហ្មមួយពួកទៀតកើតឫស្យា ទើបបានចុតិមកកើតជាសង្ខអសុរ នៅបាតមហាសមុទ្រ ជើងភ្នំព្រះមេរុ, ចំណែកឯព្រះព្រហ្មណាគាបាននាំគម្ពីរព្រះវេទមកដើម្បីថ្វាយព្រះឥសូរ តែទទួលក្តៅខ្លាំងណាស់ ទើបចុះសម្ងំក្នុងមហាសមុទ្រ គម្ពីរព្រះវេទនោះដាក់ទុកលើគោក, សង្ខអសុរឃើញដូច្នោះ ទើបគិតថាបើលួចយកទៅបោលក្នុងទឹកបង់ ព្រះព្រហ្មក៏មិនមានអ្វីនឹងប្រដៅមនុស្ស ទើបប្រែក្សសៈ (ការក្សទឹក) ឲ្យមកលួចយកទៅឲ្យ, សង្ខអសុរក៏លេបព្រះគម្ពីរនោះទុក

---

១ ជាឈ្មោះកល្ប ១ យ៉ាង ។

កូនទ្រង់ ព្រះព្រហ្មតាតាឡើងអំពីទឹកមកកេមិនឃើញព្រះគម្ពីរ ក៏មិនទៅទូលព្រះឥសូរ ៗ បើកទិព្វចក្ខុញាណទៅក៏ជ្រាបហេតុនោះ ទើបត្រាស់ឲ្យអញ្ជើញព្រះនារាយណ៍អវតារអំពីក្សីរសមុទ្រ ទៅកម្ចាត់សង្ខអសុរ ដែលកាត់មកជាមច្ឆាវតារ (ត្រីក្រាយមាស) ធំមហិមា បានច្បាំងនឹងសង្ខអសុរយ៉ាងសំបើម កូនទីបំផុតក៏ដណ្តើមយកគម្ពីរព្រះវេទពីកូនទ្រង់សង្ខអសុរមកបាន នាំយកទៅថ្វាយព្រះឥសូរ ៗ រឿងមានសេចក្តីផ្សេងគ្នាដូច្នេះ ទើបនាំឲ្យឃើញថា រឿងកូនច្បាប់ហោព្រះសមុទ្រនោះ បានមកអំពីសៃវនិកាយ ដែលកាន់សាសនព្រះសិវៈ (ឥសូរ) ជាធំ ៗ

កុមារាវតារ=អ្នកប្រាជ្ញខ្មែរបុរាណបានតាក់តែងដាក់ជាខាងក្រោយត្រា-ទាហាវតារមានរឿងតាមគម្ពីរវិស្ណុបុរាណៈថា ឫសីទុរវាសគាលបាគបុប្ផ-វិកតិ (កម្រងផ្កា) អំពីនាងទេពអប្សរហើយ ក៏ហោះកំលែងបណ្តើរទៅហាក់ដូចជាមនុស្សវិកលចរិតប្រទះនឹងព្រះឥន្ទ្រគង់ដំរីឯករ៉ាវណ ក៏ថ្វាយកម្រងមាលានោះទៅ ព្រះឥន្ទ្រទទួលដាក់លើក្បាលឯករ៉ាវណ ៗ ធុំក្លិនផ្កាក្រអូបចំឡែក ក៏យកប្រមោយចាប់យកមកបោកនឹងជើង ហើយជាន់ខ្ទេចទៅព្រះឫសីឃើញដូច្នោះក៏ក្រោធ បញ្ចេញសូរសីហនាទថា ព្រះឥន្ទ្រមើលងាយ ទើបដាក់បណ្តាសាឲ្យចាលចាញ់ពួកអសុរ ៗ ចាប់ដើមអំពីនោះមកទេវបុត្តក៏ថយចុះ ទេវតាច្បាំងនឹងអសុរគ្រាណាក៏បរាជ័យតែចាញ់ដៃអសុរជា

ដកប    ទើបទៅអង្វរសុំសេចក្ដីឈឺផ្សាលអំពីព្រះព្រហ្មឲ្យត្រឡប់មានជីវិតឡើងវិញ  ព្រះព្រហ្មក៏ណែនាំឲ្យទៅអង្វរព្រះវិស្ណុ  ទ្រង់ប្រាប់ឧបាយថា ឲ្យធ្វើពិធីកូរថ្នាំអម្ឫត  ដោយថា  អ្នកណាបានផឹកហើយមានអាយុយឺនយូរ មិនចេះស្លាប់, ដាក់ឲ្យពួកទេវតាទៅស្វែងរកគ្រឿងឱសថអំពីព្រៃភ្នំមកបង់ ចុះក្នុងក្សីរសមុទ្រ  ហើយយកភ្នំមន្ទគិរីជាឈើកូរ  យកស្ដេចនាគវាសុកី ជាខ្សែពានទាញ  ពួកទេវតានឹងអសុរនាំគ្នាទាញភ្នំមន្ទគិរីវិលទៅ  (ដូចយាំងត្បាល់ថ្មកិនម្សៅ) ស្ដេចនាគវាសុកីបានសេចក្ដីក្ដៅក្រហាយ  ក៏ព្រួសពិសចេញមក  ព្រះវិស្ណុទើបសូមឲ្យព្រះឥសូរសោយពិសកាឡកូដនោះទៅ ដើម្បីកុំឲ្យកើតក្ដីអន្តរាយដល់អ្នកដទៃ  ដោយថ្នាំពិសនោះក្ដៅខ្លាំងពេកព្រះសូរង្គព្រះឥសូរក៏រលាកខ្មៅ  ព្រះឥសូរទើបមាននាមថា  នីលកណ្ឋ  កាលទាញយូរទៅភ្នំមន្ទគិរីក៏ធ្លាយធ្លុះចុះទៅក្រោមបាតាល, តោងក្ដៅដល់ព្រះ-នារាយណ៍ៗ ក៏បែងភាគជាអណ្ដើកទៅទ្រភ្នំកុំឲ្យកប់ទៅបាន  ការកូរទើប-ធ្វើទៅបានដោយស្រួលៗ  របស់ដែលបានមកអំពីការកូរសមុទ្រទឹកដោះគោនោះ  គឺ ១ មេគោសុរភី, ២ –. វារុណី  (មេស្រា) ៣ –. ដើមបារិ-ជាត, ៤ –. ពួកទេពអប្សរ, ៥ –. ទឹកចន្ទ (ព្រះសិវៈទទួលយកតែម្នាក់ឯង), ៦ –. ទឹកពិស (ពួកនាគស្រូបអស់), ៧ –. ផ្កាឈូកផុសត្រង់កណ្ដាលមានទេវីនាមថា ព្រះស្រី (ដែលបានទៅព្រះវិស្ណុ) ៨ –. ទេវពេទ្យ

ឈ្មោះ ធន្វន្តរីស្ទួយកាជន៍ថ្នាំអម្ឫត[១] ឡើងមក ។ ខណៈនោះព្រះវិស្ណុ ទើបជំណែងអង្គជានាងអប្សរលំអលក្ខណ៍ ទៅលលួងពួកអសុរទៀ បេញពាក់ស្ថានផ្ទៃសមុទ្រនោះ ពួកទេពទិករកើតនាំគ្នាផឹកទឹកអម្ឫតតែ ១ ពួក ពួកទេវតាក៏ទៅហើយមិនស្លាប់ ទើបមាននាមថា "អមរ" រួចក៏បន្លឺ សូរសព្ទថ្វាយព្រះវិស្ណុ ពួកអសុរបែរមកមើលក៏ដឹងបានបាញ់ប្រែបពួក ទេវតា ទើបនាំគ្នាស្ទុះទៅដើម្បីនឹងផឹកទឹកអម្ឫតក៏កើតជាសង្គ្រាមដណ្ដើម ទឹកអម្ឫតទិព្វនោះឡើង ពប់ជាទេពសុរសង្គ្រាមគ្រាដំបូង, គ្រានោះពួក អសុរត្រូវស្លាប់ក្នុងទីបម្បាំងជាច្រើន ទើបបានបាញ់ពួកទេវតា ។ ក្នុង យុគនេះ នរជនរាប់អានព្រះហរិច្រើនជាបំផុតដូចមានពាក្យសរសើរថាអ្នក ណាបានថ្វាយបង្គំព្រះហរិ ទុកស្មើដូចបានថ្វាយបង្គំព្រះជាម្ចាស់ទាំង ៣ អង្គ គឺទាំងព្រះព្រហ្មទាំងព្រះសិវៈផង" ។

ក្នុងសៀវភៅនាំពិឃណ៌ស៊ុបប៉ាង ប្រាប់ថាព្រះសមុគមានសេចក្ដី ត្រឹមតែថា ព្រហ្មទៅហាន ១ មានសេចក្ដីប្រាព្រះព្រហ្មឆាគា ទើបនាំ

---

១ របស់ដែលបាននេះ មានពោលផ្សេងៗ ៗ ក្នុងសៀវភៅ Asistio mythotogy ពោលថាមាន ១- កែវកៅស្តុភាដែលព្រះវិស្ណុយកទៅប្រដាប់ព្រះឱរៈ ២- ដើមបារិជាត, ៣- គោកាមធេនុ ជាទេវីនៃសេចក្ដីមានបាន, ៤- សេះតរសោចឈ្មោះឧច្ចៃស្រពៈ ៥- ត្បូងរតន៍ព្រមទាំងនាងអប្សរាប់កោដិនឹងព្រះលក្ខ្មីព្រះហស្តកាន់ផ្កាឈូក, ៦- ព្រះធន្វន្តរីនឹងបបទពេទ្យអ្នកជំនួញក្នុងអបេរវេទផុះមកអំពីបាតសមុទ្រក្នុងទីខ្លះពោលថា ប្រាកដជារូបមាយា ។

គ្នាប្តូរមកកើតជាមច្ឆាសុរ (គឺអសុរត្រី) ហែលទៅចាប់ជើងភ្នំព្រះសុមេរុឲ្យដីជុំវិញជើងភ្នំបាក់ ព្រះឥសូរទើបអញ្ជើញព្រះនារាយណ៍ឲ្យជួយក្រោប ព្រះនារាយណ៍ប្លែងភាគជាអណ្តើកមាសចុះទៅក្រោបមច្ឆាសុរ ។ ឯរឿងកូរសមុទ្រទឹកដោះយកថ្នាំអម្រឹតនោះគ្មានពោលដល់ (រាប់ថាសេចក្តីសំខាន់មួយអន្លើ) ។

វរាហាវតារ=មានសេចក្តីក្នុងគម្ពីរត្រៃត្រិសន្ធិតពោលថា កាលលោកប្រល័យកល្បគ្រានោះ ដោយហិរណ្យាក្សៈ[1] បានបំពេញតបះចាល់តែព្រះសិវៈទ្រង់ព្រះមេត្តាប្រោសប្រទានពរទើបសំដែងឫទ្ធិមូរផែនដីទាំង ៤ ទ្វីប យកទៅទោលឯបាតាល ព្រះនារាយណ៍ទ្រង់ប្លែងភាគជាវរាហៈ (ជ្រូក) សម្បុរខ្មៅ កាយធំទំហំ ១០ យោជន៍ ខ្នាយសវែង គ្រាប់ទៅក្នុងទឹកប្រទះផែនដី ក៏យកខ្នាយឆ្កេះឡើង ហិរណ្យាក្សៈឃើញមិនសប្បាយចិត្ត ក៏ស្រែកហាមឃាត់ ព្រោះមិនចង់ឲ្យមនុស្សមានទីលំនៅអាស្រ័យ ទើបកើតច្បាំងគ្នាឡើង វរាហៈគស្ទូខ្ទេះហិរណ្យាក្សៈស្លាប់ ហើយក៏យកខ្នាយស្ទួយផែនដីមកទុកដូចដើមវិញ នៅដរាបដល់សព្វថ្ងៃនេះ ។

---

១ ហិរណ្យាក្សៈ និងឡើយជាទ្វារបាលរបស់ព្រះវិស្ណុ បានធ្វើការហាមឃាត់ពួកទេវតាដែលចូលទៅ ទើបត្រូវបណ្តាសាកើតជាទៃត្យៈ ។ (មានត)

# សម្ពុលាជាតក

## តឹសតិនិបាត សត្តមភាគ

ព្រះថ្មាឡាត់ពោធិកម យូរ-ប៉ុណ្ណ ក្រុមជំនុំប្រែព្រះត្រៃបិដក

ប្រែនិងរៀបរៀង (តមក)

កា វេធមានា គិរិកន្ទរាយ
ឯកា តុវំ តិដ្ឋសិ សញ្ញតូរុ
បុដ្ឋាសិ មេ ចាណិបមេយ្យមជ្ឈេ
អក្ខាសិ មេ នាមញ្ច ពន្ធវេ ច ។
ឱភាសយំ វនំ រម្មំ    សីហព្យគ្ឃនិសេវិតំ
កា វា ត្វមសិ កល្យាណិ    កស្ស វា ត្វំ សុមជ្ឈិមេ
អភិវាទេមិ តំ ភទ្ទេ    ទានវាហំ នមត្ថុ តេ ។

ម្នាលនាងមានភ្លៅមូល នាងឯងឈ្មោះអ្វី មកឈរម្នាក់ឯង លើជ្រោះភ្នំញាប់ញ័រ (យ៉ាងនេះ) នាងឯងកាលបើយើងសួរគណ្ដាលព្រៃដែលគួរកំណត់ដោយដៃ[១] នាងចូរប្រាប់នូវឈ្មោះនឹងផៅពង្សដល់យើង ។ ម្នាលនាងកល្យាណីជាស្រីមានខ្ទងពាក់កណ្ដាលល្អ នាងជាស្រីល្អ តើឈ្មោះអ្វី នាងជាធីតារបស់អ្នកណា ទើបញ៉ាំងព្រៃជាទីរីករាយ ដែលពួកសត្វសីហនិងខ្លាធំអាស្រ័យនៅឲ្យភ្លឺរុងរឿង ម្នាលនាងដ៏ចំរើន យើងជាអសុរ សូមសំពះនាង សូមគោរពចំពោះនាង ។

---

១ ប្រហែលជាអសុរ នឹងនាងសម្ពុលា និយាយស្ដាប់គ្នាមិនបាន ក៏សញ្ញាដោយដៃ ។

នាងសម្ពុលាបានស្តាប់ពាក្យទានវយក្សហើយក៏ឆ្លើយវិញថា

យោ បុត្តោ កាសិរាជស្ស សោត្ថិសេនាតិ តំ វិទូ
តស្សាហំ សម្ពុលា ភរិយា ឯវំ ជានាហិ ទានវ
អភិវាទេមិ ភទ្ទន្តេ សម្ពុលាហំ នមត្ថុ តេ ។
វេទេហបុត្តោ ភទ្ទន្តេ វនេ វសតិ អាតុរោ
តមហំ រោគសម្មត្តំ ឯកា ឯកំ ឧបដ្ឋហឹ ។
អហញ្ច វនមុញ្ឆាយ មធុមំសំ មិគាវិលំ
យទាហរាមិ តំ ភក្ខោ តស្ស នូនជ្ជ ជាយតិ ។

អ្នកណាជាបុត្ររបស់ស្តេចក្នុងដែនកាសី អ្នកផងតែងស្គាល់អ្នកនោះថា ជាស្តេចឈ្មោះសោត្ថិសេន ខ្លួនខ្ញុំឈ្មោះនាងសម្ពុលា ជាភរិយារបស់ស្តេចឈ្មោះសោត្ថិសេននោះ បពិត្រទានវៈ អ្នកចូរដឹងយ៉ាងនេះចុះ បពិត្រអ្នកដ៏ចំរើន ខ្ញុំឈ្មោះនាងសម្ពុលា សូមសំពះ សូមគោរពចំពោះអ្នក បពិត្រអ្នកដ៏ចំរើន ព្រះរាជបុត្រឯណា ជាបុត្ររបស់ស្តេចក្នុងដែនវិទេហៈ មានសេចក្តីក្តៅក្រហាយក្នុងចិត្ត ទើបមកនៅក្នុងព្រៃ ខ្ញុំជាស្រីម្នាក់ឯងបំរើព្រះរាជបុត្រមួយអង្គនោះ ដែលមានរោគបៀតបៀន ។ មិនតែប៉ុណ្ណោះ ខ្ញុំ (ត្រាប់ទៅ) ដើម្បីស្វែងរកផ្លែឈើក្នុងព្រៃនាំមក នឹងទឹកឃ្មុំនឹងសាច់ដែលសល់អំពីម្រឹគឯណា (ស្វាមីរបស់ខ្ញុំ) មានទឹក

យុំនឹងសាច់នោះជាអាហារ (កាលបើមិនមានអាហារ) សរីរៈរបស់ស្វាមីនោះ រមែងញាប់ញ័រក្នុងថ្ងៃនេះដោយពិត ។

ពានរយក្សនិយាយល្បួងលោមថា

កឹ វេន រាជបុត្តេន អាតុរេន ករិស្សសិ
សម្មុលេ បរិចិណ្ណេន អហំ ភត្តា ភវាមិ តេ ។

ម្នាលនាងសម្មុលា នាងធ្វើ (នូវការមូលមិត្តជាមួយ) នឹងព្រះរាជ-បុត្រជាបុគ្គលក្តៅក្រហាយដែលមានរោគមកប៉ះពាល់នៅក្នុងព្រៃធ្វើអ្វី បងនឹងធ្វើជាភស្តានៃនាង (ក្នុងថ្ងៃនេះ) ។

នាងសម្មុលាតបថា

សោកដ្តាយ ទុរត្តាយ កឹ រូបំ វិជ្ជតេ មម
អញ្ញំ បរិយេស ភទ្ទន្តេ អភិរូបតរំ មយា ។

បពិត្រអ្នកដ៏ចំរើន ខ្ញុំនឹងមានរូបល្អដូចម្តេច ព្រោះខ្ញុំជាស្រីមានសេចក្តីសោកគ្រប់សង្កត់ មានខ្លួនលំបាក (នឿយហត់ខ្លាំងណាស់ មិនសមបើអ្នកមកស្និទ្ធស្នាលទេ) អ្នកចូរទៅរកស្រីឯទៀតដែលមានរូបល្អជាងខ្ញុំ (មកធ្វើជាភរិយាចុះ) ។

ពានរយក្សនិយាយថា

ឯហិមំ គិរិមារុយ្ហ ភរិយា មយ្ហំ ចតុស្សតា
តាសំ ត្វំ បវរា ហោហិ សព្វកាមសមិទ្ធិនី ។

ឆ្វិន តារកាវណ្ណាភេ  យំ កិញ្ចិ បន សច្ចសិ
សព្វត្តំ បភុំ មយ្ហំ  រមស្សុ មយា សហ ។
នោ ចេ តុំ មហោសេយ្យំ  សម្ពុលេ ការយិស្សសិ
អលំ ត្វំ ទាតភសាយ  មញ្ញោ កត្វា ករិស្សសិ ។
តញ្ចុ សត្តជោ លុទ្ធោ  កាឡ្យាភេ បុរិសានកោ
វរេ ឆាជំ អបស្សន្តិ  សម្ពុលំ អក្កហី កុជេ ។

ម្នាលប្អូនស្រី ចូរនាងមកចុះ ចូរនាងឡើងទៅលើក្អែនេះ ស្រីពន្ធរបស់បងមានចំនួន ៤០០ នាក់ បណ្ដាស្រីពន្ធទាំងនោះ នាងឯងជាស្រីប្រសើរជាទីសម្រេចតាមសេចក្ដីប្រាថ្នាគ្រប់យ៉ាង ។ ម្នាលប្អូនស្រីដ៏មានពន្លឺដូចផ្កាយ នាងប្រាថ្នាក្នុងចិត្តចំពោះវត្ថុឯណាមួយ វត្ថុទាំងអស់នោះរបស់បងមានគ្រប់គ្រាន់ ចូរប្អូនត្រេកអរនៅជាមួយនឹងបងក្នុងថ្ងៃនេះចុះ ។ ម្នាលនាងសម្ពុលា បើនាងមិនព្រមធ្វើឲ្យភាពជាមហេសីបងទេ នាងឯងគួរនឹងបានជាអាហារក្នុងវេលាភោជនក្នុងពេលព្រឹកនេះមិនខាន ។ ឯទានវយក្សដែលមានកន្លឹសក់ ៧ ជាន់ ជាជាតិអាក្រក់មានចង្កូមលៀនចេញមកក្រៅ ជាអ្នកក្លៀវក្លាថាតែប៉ុណ្ណោះ ក៏ស្ទុះទៅចាប់នាងសម្ពុលា ទាំងអំណាចដែលមិនឃើញមានអ្នកណាមួយជាទីពឹងនៅក្នុងព្រៃ មកដាក់លើក្លៀក ។

អធិបន្នា បិសាចេន  លុទ្ធេនាមិសចក្ខុនា
សា ច សត្តុវសម្បត្តា  បតិមេវានុសោចតិ ។

ន មេ ឥទំ តជា ទុក្ខំ  យំ មំ ខាទេយ្យ រក្ខសោ
យញ្ច មេ អយ្យបុត្តស្ស មនោ ហោស្សតិ អញ្ញថា ៗ
ន សន្តិ ទេវា បវសន្តិ នូន
ន ហិ នូន សន្តិ ឥធ លោកបាលា
សហសា ករោន្តានំ អសញ្ញតានំ
ន ហិ នូន សន្តិ បដិសេធិតារោ ៗ

នាងសម្មុលា ដែលយក្សជាបិសាចជាជាតិកាក្រក់មានក្លែកសំឡឹងនូវសាមិសគ្រប់សង្កត់ ជាស្រីលុះក្នុងអំណាចនៃសត្រូវហើយ ក៏សោយសោកទៅរកស្វាមីថា យក្សស៊ីនូវខ្ញុំដោយហេតុឯណា ហេតុនោះមិនមែនជាទុក្ខដល់ខ្ញុំដូច្នោះទេ លុះតែចិត្តរបស់អយ្យបុត្ររបស់ខ្ញុំកើតមានដោយអាការៈដទៃដោយហេតុឯណា ហេតុនោះទើបជាទុក្ខដល់ខ្ញុំ ៗ នាងយំខ្លួញរៀបរាប់ទីករកដល់ពួកទេវតាថា ទេវតាទាំងឡាយនៅក្នុងទីនេះប្រហែលជាមិនមានទេដឹង ទេវតាទាំងឡាយជាលោកបាលអ្នករក្សាលោកនៅក្នុងទីនេះប្រហែលជាមិនមានទេដឹង ទេវតាទាំងឡាយអ្នកហាមឃាត់នូវពួកជនជាអ្នកមិនសង្រួម ជាអ្នកធ្វើដោយការកំហែង មិនមានទេឬ (បានជានៅស្ងៀមឈឹងយ៉ាងនេះ) ៗ

គ្រានោះ ក៏ក្តៅរំជួលដល់ព្រះឥន្ទ្រាធិរាជ ដោយតេជះសីលនៃនាងសម្មុលា អត់ទ្រាំនៅមិនបាន ទើបស្តុបពិចារណានូវហេតុនោះ ក៏បានដឹង

ប្រាកដ ក៏កាន់យកនូវដែកវុធ ហោះចុះមកដោយប្រញាប់ប្រញាល់ ឋិតនៅលើអាកាស ត្រង់ពីលើក្បាលទានវយក្ស ហើយគម្រាមថា

ឥត្ថីធមេសា បវរា យសស្សិនី
សទ្ធា សមា អតិវត្តតេជា
តស្មា តុវំ រក្ខសាទេសិ កញ្ញំ
មុទ្ធា ច ហិ សត្តធា តេ ផលេយ្យ
មា តំ ទហី មុញ្ច បតិព្វតា សា ។

នែយក្ស ! ស្រីនេះជាស្រីមានយស ជាស្រីប្រសើរជាងស្រីទាំងឡាយ ជាស្រីមានសណ្ដាប់ធ្នាប់ មានកិរិយាមារយាទស្មោះស្ម័គ្រ មានតេជះរុងរឿងដូចជាអណ្ដាតភ្លើង (មិនមែនជាស្រីផ្ដេសផ្ដាសទេ) បើឯងស៊ីនាងកញ្ញានេះ ក្បាលអ្នកឯងនឹងបែកចេញជា ៧ ភាគមិនខាន អ្នកឯងកុំកំដៅ (ទូរនាងកញ្ញានេះ) អ្នកឯងចូរលែងទៅ ព្រោះស្រីនេះជាស្រីមានប្ដីទេតើ ។

ទានវយក្សបានស្ដាប់នូវពាក្យនោះហើយ ក៏ភិតភ័យតក់ស្លុតញាប់ញ័រអស់ទាំងខ្លួន ទើបលែងនាងនោះប្រញាប់ ៗ ព្រះភទ្រាធិកជក៏ចាប់យក្សនោះចងដោយប្រាក់ ហើយលែងទៅក្នុងចន្លោះភ្នំទី ៣ ដោយគិតថា កុំឲ្យវាមកបៀតបៀនដល់នាងនេះទៀតឡើយ ៗ ទើបឲ្យឱវាទដល់នាងសម្ពុលាថា នាងកុំមានសេចក្ដីភិតភ័យឡើយ ចូរនាងត្រឡប់

ទៅចម្រើស្វាមីវិញចុះ ។ សក្កទេវរាជលុះឲ្យឱវាទដល់នាងរួចហើយ ក៏ត្រឡប់ទៅកាន់ឋានលំនៅវិញ ។ វេលានោះព្រះអាទិត្យក៏អស្តង្គតទៅហើយ នាងដើរទៅដោយពន្លឺព្រះច័ន្ទ មានសេចក្តីទុក្ខសោកក្រៀមក្រំនឹកដល់ស្វាមីដែលនៅក្នុងអាស្រមម្នាក់ឯង ប្រហែលជាគង់ចាំមើលដំណើរមកនៃអញទេដឹង ។ ចំណែកឯសោត្ថិសេនលុះដល់ពេលរសៀលល្ងាចហើយ មិនឃើញនាងត្រឡប់មកអាស្រម ក៏ចុះទៅចាំនៅមាត់ទ្វារក្រៅចាំមើលផ្លូវនាង ។

ព្រះបរមលោកនាថ ទ្រង់ប្រកាសសេចក្តីនេះថា

សា ច អស្សមមាគញ្ឆិ បមុត្តា បុរិសាទកា
ធិត្តី ជលិនសកុណីវ គតសិង្គំវ អាលយំ ។
សា តត្ថ បរិទេវេសិ រាជបុត្តី យសស្សិនី
សម្មុលា ឧតុមត្តក្ខា វនេ នាថំ អបស្សន្តី ។
សមណេ ព្រាហ្មណេ វន្ទេ សម្បន្នចរណេ ឥសេ
រាជបុត្តំ អបស្សន្តី តុម្ហិ សរណំ គតា ។
វន្ទេ សីហេ ច ព្យគ្ឃេ ច យេ ច អញ្ញេ វនេ មិគា
រាជបុត្តំ អបស្សន្តី តុម្ហិ សរណំ គតា ។
តិណា លតានិ ឱសធ្យោ បព្វតានិ វនានិ ច
រាជបុត្តំ អបស្សន្តី តុម្ហេ សរណំ គតា ។

ឥង្ឃ ឥន្ទីវរីសាមំ        រត្តនក្ខត្តមាលិនំ
រាជបុត្តំ អបស្សន្តី        តុម្ហម្ហិ សរណំ គតា ។
ឥង្ឃ កកិរសឹ គត្តិ        វេសត្តំ បដិគ្គហំ
រាជបុត្តំ អបស្សន្តី        តុម្ហម្ហិ សរណំ គតា ។
ឥង្ឃ អហំ បញ្ចរាជ-        សេដ្ឋំ ហិមវន្តំ សិលុច្ចយំ
រាជបុត្តំ អបស្សន្តី        តុម្ហម្ហិ សរណំ គតា ។

លុះនាងសម្តុលារួចពីកណ្តាប់ដៃយក្សប្រែសកំណាចហើយក៏ត្រឡប់មកកាន់អាស្រមវិញ ដូចជាមេបក្សីបាក់បែកទ្រនំ ហើយមកកាន់ទ្រនំដើមវិញ ពុំនោះដូចមេគោបាក់ស្នែងមកកាន់កន្លែងវិញ នាងនោះជារាជបុត្រីជាស្រីមានយស មានក្តុកគន់ដោយរដូវ មកដល់អាស្រមគេមើលស្វាមីមិនឃើញ ក៏ទ្រង់ព្រះកន្សែងក្នុងអាស្រមនោះដោយពាក្យថា ខ្ញុំម្ចាស់សូមថ្វាយបង្គំចំពោះពួកសមណព្រាហ្មណ៍ទាំងអស់ទាំងឡាយ ដែលមានការប្រព្រឹត្តប្រិបូណ៌ ខ្ញុំម្ចាស់កាលបើមិនបានឃើញព្រះរាជបុត្រជាស្វាមីទេ សូមដល់នូវលោកជាទីពឹង ៗ ខ្ញុំម្ចាស់សូមថ្វាយបង្គំចំពោះពួកសីហៈខ្លាធំ និងពួកម្រឹគ ដែលអាស្រ័យនៅក្នុងព្រៃ ខ្ញុំម្ចាស់កាលបើមិនបានឃើញនូវព្រះរាជបុត្រទេ សូមដល់នូវលោកទាំងឡាយជាទីពឹង ៗ ខ្ញុំម្ចាស់សូមថ្វាយបង្គំនូវស្មៅរល្វៀ ថ្នាំឱសថគុម្ពនិងព្រៃទាំងឡាយ ខ្ញុំម្ចាស់កាលបើមិនឃើញនូវព្រះរាជបុត្រទេ សូមដល់នូវលោកជាទីពឹង ៗ

ខ្ញុំម្ចាស់សូមថ្វាយបង្គំនូវរបៀបផ្កាយក្នុងក្រៃ ដែលមានពណ៌ដូចផ្កាយ ពជត្រីក ខ្ញុំម្ចាស់កាលបើមិនបានឃើញនូវព្រះពជបុត្រទេ សូមដល់នូវលោកជាទីពឹង ៗ ខ្ញុំម្ចាស់សូមថ្វាយបង្គំនូវស្ទឹងឈ្មោះកតិសើជាទីទទួលរបស់ស្ទឹងតាំងឡាយដែលហូរមក ខ្ញុំម្ចាស់កាលបើមិនឃើញនូវព្រះពជបុត្រទេ សូមដល់នូវលោកជាទីពឹង ៗ ខ្ញុំម្ចាស់សូមថ្វាយបង្គំនូវភ្នំហិមពាន្ត ជាស្តេចភ្នំដ៏ប្រសើរ ដែលមានថ្នាសត្រដួចឡើង ខ្ញុំម្ចាស់កាលបើមិនបានឃើញនូវព្រះពជបុត្រទេ សូមដល់នូវលោកជាទីពឹង ៗ

គ្រានោះ សោត្ថិសេន ឃើញនាងយំសោកខ្សឹកខ្សួលខ្លាំងយ៉ាងនេះ ទ្រង់ព្រះតម្រិះថា នាងនេះយំសោកអ្វីខ្លាំងម្ល៉េះ អញមិនបានដឹងហេតុនេះសោះ បើសិនជានាងធ្វើនូវអំពើបែបនេះ ដោយសេចក្តីស្រឡាញ់ចំពោះអញមែន ហឫទ័យរបស់នាងមុខជានឹងបែកធ្លាយមិនខាន បើដូច្នោះគួរអញនឹងទៅសាកសួរឲ្យដឹងហេតុនោះ ៗ ទើបស្តេចយាងទៅគង់នៅទៀបទាត់ទ្វារអាស្រម ៗ នាងចេះតែយំសោកដើរទៅមក លុះឃើញស្វាមីហើយក្រាបថ្វាយបង្គំទៀបបាទទូលសួរថា ចុះព្រះស្វាមីយាងទៅឯណាបាត់ ខ្ញុំម្ចាស់ដើររកមិនឃើញ ៗ ស្វាមីស្តីបន្ទោសថា

អតិសាយំ រតាគតញ្ចិ រាជបុត្តិ យសស្សិនិ
កេន ទុដ្ឋ សមាគញ្ចិ កោ តេ បិយតរោ មយា ៗ

បើនាងកដបុត្រី ជាស្រីមានយស មកក្នុងវេលាយប់ម្ល៉េះហ្ន៎ ! នាងមកជាមួយនឹងអ្នកណា ក្នុងថ្ងៃនេះ អ្នកណាជាទីស្រឡាញ់របស់នាងជាងអញទៅទៀត ( ថ្ងៃនេះម្ដេចក៏មិនដូចថ្ងៃមុន ) ៗ

នាងក្រាបបង្គំទូលតាមដំណើរនោះថា បពិត្រព្រះអយ្យបុត្រ ខ្ញុំម្ចាស់សូមទោស តាមតែព្រះអង្គមេត្តាប្រោសចុះ កាលដែលខ្ញុំម្ចាស់បេញទៅព្រៃបេះផ្លែឈើ ហើយត្រឡប់មកវិញ មានអសុរមួយចិត្តអាក្រក់និយាយលួងលួងខ្ញុំម្ចាស់ដោយសេចក្ដីស្នេហា ខ្ញុំម្ចាស់មិនព្រមដោយពាក្យលួងនោះ ក៏ស្ទុះមកចាប់គម្រាមថា បើនាងឯងមិនព្រមតាមអញទេ អញនឹងស៊ីនាងឯងជាអាហារមិនខាន ៗ ខ្ញុំម្ចាស់មានសេចក្ដីសោយសោកចំពោះហេតុនោះ

ឥទំ ខោហំ ធនទេចំ   កហិតា តេន សត្តុនា
ន មេ ឥទំ តថា ទុក្ខំ   យំ មំ ខាទេយ្យ រក្ខសោ
យញ្ច មេ អយ្យបុត្តស្ស   មនោ ហេស្សតិ អញ្ញថា ៗ

ខ្ញុំម្ចាស់ដែលសត្រូវនោះចាប់បាន ក៏ពោលពាក្យនេះនឹងយក្សថា យក្សស៊ីនូវខ្ញុំដោយហេតុឯណា ហេតុនោះមិនមែនជាទុក្ខដល់ខ្ញុំទេ លុះតែចិត្តអយ្យបុត្ររបស់ខ្ញុំកើតមានដោយអាការដទៃ ដោយហេតុឯណា ហេតុនោះ ទើបជាទុក្ខដល់ខ្ញុំ ៗ ពេលនោះ មានស្ដេចនៃទេវតាមក

ស្រែកគម្រាមយក្សៗ ក៏លែងខ្ញុំម្ចាស់ ទើបខ្ញុំម្ចាស់បានរួចមកដល់ពេលថ្ងៃនេះ ។

ស្វាមីតប - ម្នាលនាងដ៏ចំរើន ពាក្យនេះលើកទុកសិនចុះ ធម្មតាពាក្យសច្ចៈរបស់មាតុគ្រាម គេជឿបានដោយក្រណាស់ ព្រោះថាពួកជនអ្នកដើររកស៊ីធ្វើការក្នុងព្រៃហិមពាន្តនោះមានច្រើនណាស់ អ្នកណាគេនឹងជឿនាងឯងបាន ។

ចោរីនំ ពហុពុទ្ធីនំ យាសុ សច្ចំ សុទុល្លភំ

ថីនំ ភាវោ ទុរាជានោ មច្ឆស្សេវោទកេ គតំ ។

ពាក្យសច្ចៈរបស់ពួកស្រីចោរ មានមាយាច្រើន គេរកបានដោយក្រណាស់ ភាពគឺឫកមាយារបស់ស្រីទាំងឡាយ ក៏គេដឹងបានដោយក្រដូចជាដំណើរត្រី ដែលនៅក្នុងទឹក (មិនអាចនឹងកំណត់បានទេ) ។

នាងទូលតប - បពិត្រព្រះអយ្យបុត្រ បើព្រះអង្គមិនជឿចិត្តខ្ញុំម្ចាស់ទេ ខ្ញុំម្ចាស់សូមបួងសួងដោយកំឡាំងសច្ចធម៌របស់ខ្ញុំម្ចាស់ ចំពោះរោគព្រះអង្គក្នុងពេលឥឡូវនេះ បើខ្ញុំម្ចាស់មានចិត្តត្រង់នឹងព្រះអង្គពិតមែន សូមឲ្យរោគនេះរម្ងាប់ទៅភ្លាម ហើយនាងកាន់យកទឹកមកស្រោចពីលើព្រះសិរស្វាមីដោយពាក្យសច្ចៈថា ។

តថា មំ សច្ចំ បាលេតុ បាលយិស្សតិ ចេ មមំ

យថាហំ នាភិជានាមិ អញ្ញំ បិយតរំ តយា

ឯតេន សច្ចវជ្ជេន ព្យាធិ តេ វូបសម្មតុ ។

ខ្ញុំម្ចាស់មិនស្គាល់នូវបុគ្គលដទៃ ជាទីស្រឡាញ់ជាងព្រះអង្គយ៉ាងណា សូមពាក្យសច្ចៈរក្សានូវខ្ញុំម្ចាស់យ៉ាងនោះ បើពាក្យសច្ចៈទីទេរក្សានូវខ្ញុំម្ចាស់ ដោយពាក្យសច្ចៈនេះ សូមឲ្យព្យាធិរបស់ព្រះអង្គស្ងប់រម្ងាប់ទៅដោយស្រួពន់ ។

លុះនាងពោលពាក្យសច្ចៈរួចហើយ រោគឃ្លង់ក៏ស្ងប់រម្ងាប់ទៅមួយរំពេច ដូចជាគេយកថ្នាំទិព្យមកស្រោចលាងជម្រះអស់មន្ទិល ទៅជាមានពណ៌សម្បុរល្អដូចមាស ។

សោត្ថិសេនឧបរាជ ដឹងថារោគនោះរម្ងាប់ទៅដោយសច្ចធម៌របស់នាងក៏មានសេចក្ដីរីករាយជឿជាក់ក្នុងព្រះទ័យថា នាងនេះមានចិត្តស្មោះត្រង់ចំពោះព្រះអង្គមែន ។

ក្សត្រទាំងពីរអង្គលុះនៅក្នុងព្រៃនោះបានពីរបីថ្ងៃ ក៏ត្រឡប់ទៅនៅក្នុងនគរវិញ ចូលទៅអាស្រ័យនៅក្នុងឧទ្យានរបស់ព្រះបិតា ។ ព្រះវរបិតាបានជ្រាបថាកូនទាំងពីរត្រឡប់មកវិញហើយ ក៏ចាត់ចែងរៀបចំពិធីអភិសេកបុត្រឲ្យសោយរាជ្យស្នងព្រះអង្គ លើកនាងសម្ពុលាជាអគ្គមហេសីធំ ។ ព្រះវរបិតាក៏ចេញបួសជាតាបសឥសីអាស្រ័យនៅក្នុងឧទ្យាននោះ ។

ព្រះបាទសោត្ថិសេន តាំងតែពីបានសោយរាជ្យគ្រាន់តែតាំងនាងសមុទ្ទលាឲ្យធ្វើជាអគ្គមហេសី តែមិនដែលទឹកនាឲ្យប្រយោជន៍ណាមួយដល់នាងឡើយ ទាំងសុខទុក្ខយ៉ាងណា ក៏ព្រះអង្គមិនជ្រាប មានព្រះទ័យត្រេកត្រអាលតែនឹងពួកស្រីជាបរិវារ នាងមានសេចក្ដីព្រួយព្រះទ័យខ្លាំងណាស់ សោយក្រយាស្ងោយមិនបាន ទៅជាស្គាំងស្គមរីងរៃស្លេកស្លាំងព្រះភក្ត្រ មិនមានសេចក្ដីសុខពេលណាមួយឡើយ នាងនឹកដល់ហេតុខាងដើមថា ស្ដេចនេះដែលបានសោយរាជ្យថ្កុំថ្កើងប៉ុណ្ណោះនេះ ក៏ព្រោះតែអញ កាលដែលកើតរោគពេញទាំងព្រះកាយ ហើយចេញពីនគរទៅនៅក្នុងព្រៃតែពីរនាក់ ខ្លួនអញឥតនឹកដល់ការនឿយហត់ខំប្រឹងថែរក្សាព្យាបាលរោគដរាបដល់ស្ងាប់ទៅបាន ឥឡូវដល់បានសេចក្ដីសុខហើយ ឥតមាននឹកដល់សេចក្ដីទុក្ខលំបាកខាងដើម ខ្លួនអញជាស្រីកើតមកអភ័ព្វណាស់ហ្ន៎! ស្លាប់ទៅវិញប្រសើរជាង រស់នៅឥតអំពើ ៗ ទើបនាងចូលទៅក្រាបថ្វាយបង្គំព្រះតាបសជាបិតាឲ្យលោកជួយស្រាយនូវសេចក្ដីទុក្ខព្រួយ ក្នុងពេលដែលលោកនិមន្តមកធ្វើភត្តក្នុងប្រាសាទ ៗ

ព្រះតាបសបានឃើញនាងមានសរីរៈស្គាំងស្គមស្លេកស្លាំង ក៏សួរថា

យេ កុញ្ជរា សត្តសតា ឧឡារា
រក្ខន្តិ រត្តិន្ទិវំ ឧយ្យុតាវុធា

ឆន្នក្កោរញ្ញ សតានិ សោឡស
ការជំវិជេ បវស្សសិ កន្ទេ សត្តហេ ។

ម្នាលនាងជំទាវ ដំរីទាំង ៧០០ ជាសត្វមានកំឡាំងដ៏លើសលុប មានអារុងរៀបចំដាក់គ្រឿងអស់លោយប់ទឹងថ្ងៃ ពួកខ្វាន់ជ ១ ពាន់៦ហែនាក់ (គឺនៅតាំងក្រោមអស់កាលជាទិព្វ) ក្រុមនាងឃើញទូលសព្រះជួបម្តេចបាន (ឬមួយនាងមានហេតុជួបម្តេចបានជាស្តាំងស្តុមមេ៉ះ) ។

ទើបនាងទូលព្រះវេស្សន្តរថា

អលង្កតាយោ បទុមុត្តរត្ថា
វិរាគិតា បស្សតិ ហំសគន្ធា
តាសំ សុណិត្វា មិតគីតវាទិតំ
ននាទិ មេ តាត តទា យថា បុរេ ។
សុវណ្ណសង្កច្ចធរា សុវត្ថា
អលង្កតា មានុសិយច្ឆរូបមា
សេណោបិយា តាត អនិន្ទិតង្គិយោ
ខត្តិយកញ្ញា បដិលោភយន្តិ នំ ។
សចេ អហំ តាត តទា យថា បុរេ
បតិ តំ ឧញ្ញាយ បុនា វជេ ករ
សម្មានយេ តំ ន ច មំ វិនាយនេ

នគោធិ មេ តាត គតោ វរំ សិយា ។
យមន្ថុតានេ វិរុឡ្ហស្មិំ ធិបាតេ
ជាវី វិមដ្ឋាករណា អលង្កតា
សព្វង្គុបេតា បតិនោ ច អម្បិយា
អវជ្ឈ តស្សា មរណំ គតោ វរំ ។
អបិ ចេ ឧលិង្គា ករណា អជាតិយា
កាជាទុតិយា បតិនោ ច សា បិយា
សព្វង្គុបេតាយបិ អម្បិយាយ
អយមេវ សេយ្យោ ករណាបិ យា បិយា ។

បពិត្រព្រះបិតា ព្រះស្វាមីឃើញខ្ញុំស្រីដែលគាក់កែងកាយ មានៈសម្បុរស្បែកដូចជាស្រទាប់ផ្កាឈូក មានសរីរៈលាបស្រឡាបខ្លួនក្រៀងក្រអូបដ៏វិសេស មានសំឡេងក្ដួបជាសំឡេងសត្វពាន្យ ស្ដាប់ទៅបាម្រៀងនិងប្រាំដែលគេត្រូវពាក់ពេរបស់ពួកស្រីទាំងនោះ ឥឡូវនេះព្រះស្វាមីរបស់ខ្ញុំម្ចាស់មិនប្រព្រឹត្តដូចក្នុងកាលមុនទេ ។ បពិត្រព្រះវរបិតា ពួកស្រីមានរូបល្អទ្រទ្រង់ខ្លួនសង្ហារមាស គាក់កែងខ្លួនដូចស្រីអប្សរក្នុងមនុស្សលោក ជាទីស្រឡាញ់នៃស្ដេចសោត្ថិសេន ជាស្រីមានកងកាយដែលអ្នកផងនិតិះដៀលមិនបាន ជាស្ត្រីយកញ្ញាវែងប្រលោមព្រះស្វាមីនោះឲ្យជាប់ព្រះទ័យបាន ។ បពិត្រព្រះបិតា ប្រសិនបើខ្ញុំម្ចាស់ពិញ្ញមនូវព្រះ

ស្វាមីក្នុងព្រៃទៀត ដោយការស្មើនឹងរូបផ្ទៃឈើដូចក្នុងកាលមុនដូច្នេះ ព្រះស្វាមីកប់អានខ្ញុំម្ចាស់ក្តី មិនកប់អានខ្ញុំម្ចាស់ក្តី បពិត្រព្រះបិតា ព្រោះហេតុនោះ ព្រៃនោះឯង ប្រសើរជាទីកើតសម្បត្តិក្នុងក្រុងពារាណសីនេះទៅទៀត ។ នាងនារីឯណា កើតក្នុងត្រកូលមានបាយនឹងទឹកបរិបូណ៌ ដែលគេចាត់ចែងហើយជាអ្នកមានគ្រឿងប្រដាប់ដ៏ល្អគាប់វិសេស គាត់តែងខ្លួនប្រកបដោយអង្គគ្រប់យ៉ាង តែមិនជាទីស្រឡាញ់របស់ប្តី ឬជាស្រីឥតកូន សេចក្តីស្លាប់របស់នារីនោះ ប្រសើរជាងការនៅជាយកាសនោះទៅទៀត ។ បើស្រីឯណា ចាល់ក្រក់ក្រពាល្ងង់ខ្លៅ មានតែកខ្វលជាគំរប់ពីរនឹងខ្លួន តែស្រីនោះជាទីស្រឡាញ់របស់ប្តី ស្រីឯណានោះជាស្រីកំព្រា តែជាទីស្រឡាញ់របស់ប្តី ស្រីនេះឯងប្រសើរជាងស្រីដែលប្រកបដោយអង្គគ្រប់យ៉ាងតែមិនជាទីស្រឡាញ់របស់ប្តីទៅទៀត ។

នាងសម្ពុលា បានទូលហេតុបន្ទះបង្អាប់ខ្លួនឯង ចំពោះព្រះវរបិតារបស់ព្រះគ្រប់ហើយ ទើបតាបសជាបិតាឲ្យទៅអញ្ជើញស្តេចមកនឹងឲ្យដំបូន្មានតាមគន្លងធម៌ ៈ ម្នាលបុត្រ កាលដែលបុត្រមានកេតចេញពីទីនេះទៅអាស្រ័យនៅក្នុងព្រៃ នាងនេះតាមទៅបម្រើ ធ្វើកេតឲ្យទ្រាប់បាន លុះត្រឡប់មកគ្រប់គ្រងរាជសម្បត្តិវិញ ម្តេចហើយក៏ភ្លេចហេតុដើម ទាំងភ្លេចសេចក្តីសុខទុក្ខរបស់នាងនេះទៅវិញ នែហោតូស្សេនបុត្រ ឯការ

ទ្រុស្តមិត្តយ៉ាងនេះមិនល្អទេ បាបធ្ងន់ណាស់ ។ ព្រះតាបសជាបិតា បន្ទោសយ៉ាងនេះហើយ ទើបឲ្យឱវាទតទៅទៀត

សុទុល្លភិត្ថី បុរិសស្ស យា ហិតា
ភត្តិត្ថិយា ទុល្លភោ យោ ហិតោ ច
ហិតា ច តេ សីលវតី ច ភរិយា
ជនិន្ទ ធម្មំ ចរ សម្មុលាយ ។

ម្នាលបាជាធំក្នុងដែន ស្រីឯណាជាគុណដល់បុរស ស្រីនោះគេរកបានដោយក្រក្រៃលែង បុរសឯណាជាគុណដល់ស្រី បុរសនោះក៏គេរកបានដោយក្រដែរ ភរិយារបស់បាជាគុណដល់បាផង មានសីលផង បាចូរប្រព្រឹត្តធម៌ (ដោយការរួបរួមជាមួយគ្នា) នឹងនាងសម្មុលាចុះ ។

ព្រះតាបសឲ្យឱវាទហើយ ក៏និមន្តទៅកាន់អាស្រមក្នុងឧទ្យាននោះវិញ ។

ព្រះបាទសោត្ថិសេនរាជ ទ្រង់ត្រាស់ហៅនាងសម្មុលាមកខមាទោសថា ម្នាលនាងដ៏ចំរើន សេចក្ដីកំហុសដែលយើងធ្វើហើយអស់កាលយូរ សូមនាងអត់ទោសដល់យើងដោយសេចក្ដីសង្គ្រោះ ។ ទើបព្រះអង្គពោលពាក្យប្ដេជ្ញាចំពោះនាងថា

សចេ តុវំ វិបុលេ លទ្ធភោគេ
ឥស្សាវតិណ្ណា មរណំ ឧបេសិ

## អហាញុំ ទេ កាដ្ឋ ៩មា ពជកញ្ញា

## សត្វេ ទេ វិជឈកាភ កភិម ។

ម្ចាស់នាងនាងកោតគេច្រើន  បើនាងមិនលុះក្នុងអំណាចនៃសេចក្តីច្រណែនដល់ផល់មរណៈទេ  យើងនឹងពួកពួកញាតិអស់របស់នាងនេះ នឹងធ្វើតាមពាក្យរបស់នាងដរាបទៅ ។

ចាប់តាំងពីថ្ងៃនេះទៅ  ព្រះរាជាកោសលសេនបានធ្វើការរួបរួមមូលមិត្ត សេចក្តីសុខទុក្ខជាមួយនឹងអគ្គមហេសី  តាំងប្រគល់កិច្ចការគាថមុខក្រសួងរបស់នាងឲ្យធ្វើតាមត្រូវការ  ទឹងវាគ់ថែងធ្វើបុណ្យទានតាមបវេណីរបស់មហាក្សត្រ ជាផ្លូវជាដំណើរទៅកាន់សុគតិភពតាមយថាកម្ម ។ ឯព្រះតាបសជាបិតាក៏បានសម្រេចឈានសមាបត្តិ ជាផ្លូវជាដំណើរទៅកាន់ព្រហ្មលោក ។

ព្រះបរមសាស្តា  ទ្រង់សំដែងអតីតជាតិនៃនាងមល្លិកាទេវីនេះឲ្យឃើញច្បាស់ ។ ម្ចាស់ភិក្ខុទាំងឡាយ  នាងមល្លិកាទេវីនេះ ជាស្រីឆ្លៀវឈ្លាសប្រកបដោយកល្យាណធម៌ច្រើនយ៉ាង  បុនប្រសប់ខាងកិច្ចការគ្រប់យ៉ាង មានធ្វើកុសលជាដើម បានឈ្មោះថាជាបតិទេវតា មិនតែក្នុងវេលានេះទេ  កាលពីព្រេងនាយកើតជានាងសម្មុហោ នោះក៏ដូច្នោះដែរ ។

ព្រះអង្គទ្រង់ប្រជុំជាតកអំពីអតីតជាតិ នឹងក្នុងបច្ចុប្បន្ននេះ ឯនាងសម្មុលាទេវី បានមកជានាងមល្លិកាទេវី ស្តេចសោត្ថិសេន បានមកជាព្រះបាទកោសល តាបសជាបិតា ក៏គឺអង្គតថាគតហ្នឹងឯង ។

—

ចប់ សម្មុលជាតក

តីសតិនិបាត សត្តមភាគ ។

អរិយសច្ចជាពុទ្ធភាសិត

# លោកគ្រូព្រះអាចារ្យ ប៉ាង - ខាត់

រៀបរៀង ( តមក )

អវិជ្ជាដាច់ទៅហើយ វិជ្ជាក៏កើតឡើង ងងឹតបាត់ទៅហើយ ពន្លឺក៏កើតឡើងដល់តថាគតដែលជាអ្នកមិនប្រមាទ ព្យាយាមដុតកំដៅកិលេសឲ្យក្តៅ បញ្ជូនចិត្តទៅកាន់ព្រះនិព្វានដោយពិត ។

ម. ម. ពោធិរាជកុមារសូត្រ ២៤ - ៣៩៩ - ២៥៩.

## កាលទ្រង់មិនទាន់ត្រាស់ដឹងអរិយសច្ចក៏ទ្រង់មិនទាន់បានព្រះនាមថា ត្រាស់ដឹងអនុត្តរសម្មាសម្ពោធិញ្ញាណ

ម្នាលភិក្ខុទាំងឡាយ! ញាណទស្សនៈ គឺការឃើញដោយប្រាជ្ញាតាមពិត ក្នុងអរិយសច្ចទាំងឡាយ ៤ នេះ ជាមានបរិវដ្ត ៣ មានអាការៈ ១២ នៃតថាគតមិនទាន់បរិសុទ្ធវិសេសស្អាតបាតនៅដរាបណា, ម្នាលភិក្ខុទាំងឡាយ! តថាគត ក៏មិនទាន់បានទាយថាជាអ្នកត្រាស់ដឹង បានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ និងទេវតា ព្រមទាំងមនុស្ស ដរាបនោះ ។ តែកាលណា ញាណទស្សនៈ គឺការឃើញដោយប្រាជ្ញាតាមពិត ក្នុងអរិយសច្ចទាំងឡាយ ៤ នេះ ជាមានបរិវដ្ត ៣ មានអាការ ១២ នៃតថាគត បរិសុទ្ធវិសេសស្អាតបាត, ម្នាលភិក្ខុទាំងឡាយ! កាលនោះ ទើបតថាគតបានទាយថាជាអ្នកត្រាស់ដឹង បាន

ត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ក្នុងលោកព្រមដោយទេវលោក មារលោក ព្រហ្មលោក ក្នុងពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ទាំងទេវតាព្រមទាំងមនុស្ស ។ មិនតែប៉ុណ្ណោះ ញាណទស្សនៈ កើតឡើងដល់តថាគត វិមុត្តិតថាគតមិនត្រឡប់កំរើកញាប់ញ័រ ជាតិនេះជាជាតិទីបំផុត តទៅនេះភពថ្មីទៀត មិនមានទៀតទេដូច្នេះ ។

មហាវារៈ សំ. ១៩-៥៣០-១៦៧០

## ព្រះពុទ្ធអង្គទ្រង់ព្រះនាមថា សម្មាសម្ពុទ្ធ ព្រោះទ្រង់ត្រាស់ដឹងអរិយសច្ច ៤

ម្នាលភិក្ខុទាំងឡាយ! អរិយសច្ចទាំងឡាយមាន ៤ ប្រការ, អរិយសច្ច ៤ ប្រការតើអ្វីខ្លះ? គឺ សេចក្តីពិតដ៏ប្រសើរគឺទុក្ខ ១, សេចក្តីពិតដ៏ប្រសើរគឺហេតុប្រជុំកើតឡើងនៃទុក្ខ១, សេចក្តីពិតដ៏ប្រសើរគឺធម៌ជាគ្រឿងរំលត់ទុក្ខ ១; សេចក្តីពិតដ៏ប្រសើរគឺសេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខ ១, ម្នាលភិក្ខុទាំងឡាយ! នេះឈ្មោះថាអរិយសច្ច ៤ ប្រការ ។ ម្នាលភិក្ខុទាំងឡាយ! ព្រោះតែបានត្រាស់ដឹងតាមពិត នូវអរិយសច្ចទាំងឡាយ ៤ នេះឯង ទើបតថាគតបាននាមដែលអ្នកប្រាជ្ញគេពោលថា: "អរហន្ត សម្មាសម្ពុទ្ធ" ដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ! ព្រោះហេតុនោះអ្នកទាំងឡាយគប្បីធ្វើសេចក្តីព្យាយាម ដើម្បីឲ្យដឹងច្បាស់ថា:

(នៅមានត)